ADB ASIAN DEVELOPMENT BANK

ក្រសួងពាណិជ្ជកម្ម Ministry Of Commerce

Trade Training and Research Institute

ADBInstitute

# របាយការណ៍ស្ថាពរ

## TA-៦៦១៨ REG

## ការបង្កើតមជ្ឈដ្ឋានអំណោយផលសម្រាប់សេដ្ឋកិច្ចឌីជីថល ប្រទេសកម្ពុជា

ជំនាញការឯករាជ្យ៖ វេជ្ជ. Dalma R Demeter

លោក Samdy Lonh

កាលបរិច្ឆេទ៖ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣

# តារាងមាតិកា

សេចក្តីផ្តើម ........ 1
ព្រឹត្តិការណ៍សំខាន់ទី១ ........ 5
ព្រឹត្តិការណ៍សំខាន់ទី២ ........ 9
ព្រឹត្តិការណ៍សំខាន់ទី៣ ........ 12
ព្រឹត្តិការណ៍សំខាន់ទី៤ ........ 15
ព្រឹត្តិការណ៍សំខាន់ទី៥ ........ 16
សេចក្តីសន្និដ្ឋាន ........ 21
ឧបសម្ព័ន្ធទី ១ ........ 23
ឧបសម្ព័ន្ធទី២ ........ 27
  មគ្គុទ្ទេសន៍ណែនាំសម្រាប់វគ្គសិក្សាទី១ ........ 27
  មគ្គុទ្ទេសន៍ណែនាំសម្រាប់វគ្គសិក្សាទី២ ........ 29
  មគ្គុទ្ទេសន៍ណែនាំសម្រាប់វគ្គសិក្សាទី៣ ........ 31
ឧបសម្ព័ន្ធទី ៣ ........ 35
  សេចក្តីផ្តើមអំពីវេបសាយត៍នៃវគ្គសិក្សាអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ 35
  វីឌីអូមេរៀនទីមួយ ........ 36
  ធនធានអានសម្រាប់មេរៀនទីមួយ ........ 37
  សំណួរវាយតម្លៃ ........ 37
  សំណួរមតិត្រឡប់ ........ 37
  ទំព័រវគ្គសិក្សាអំពីសិទ្ធិ និងកាតព្វកិច្ចនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ 38
  ទំព័រវគ្គសិក្សាអំពីសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត ........ 39
  គំរូវិញ្ញាបនបត្របញ្ចប់ការសិក្សា ........ 40
ឧបសម្ព័ន្ធទី៤ ........ 41
  ការចុះឈ្មោះ និងការបញ្ចប់វគ្គសិក្សាសាកល្បង ........ 41

ឧបសម្ព័ន្ធទី៥ ........ 48
សំណួរមតិត្រឡប់ ........ 48
ឧបសម្ព័ន្ធទី៦ ........ 49
ចំណាត់ថ្នាក់ការអនុវត្តសាកល្បង ........ 49
ឧបសម្ព័ន្ធទី៧ ........ 52
មតិត្រឡប់ពីការធ្វើតេស្តសាកល្បង ........ 52
ឧបសម្ព័ន្ធទី៨ ........ 57
ការចុះឈ្មោះសម្រាប់វគ្គសិក្សា និងការបញ្ចប់ នៅពេលចេញផ្សាយលើកចុងក្រោយ ........ 57
ឧបសម្ព័ន្ធទី៩ ........ 60
ចំណាត់ថ្នាក់វគ្គសិក្សានៅពេលចេញផ្សាយលើកចុងក្រោយ ........ 60
ឧបសម្ព័ន្ធទី១០ ........ 63
មតិត្រឡប់ពីការចេញផ្សាយលើកចុងក្រោយ ........ 63
ឧបសម្ព័ន្ធទី១១ ........ 67
លទ្ធផលនៃការចុះឈ្មោះ និងការបញ្ចប់នៅក្នុងការអនុវត្តសាកល្បង និងការចេញផ្សាយលើកចុងក្រោយ ........ 67

| | |
|---|---|
| ធនាគារអភិវឌ្ឍន៍អាស៊ី | TA-៦៦១៨ REG |
| ឈ្មោះគម្រោង | ការបង្កើតមជ្ឈដ្ឋានអំណោយផលសម្រាប់សេដ្ឋកិច្ចឌីជីថល |
| លេខគម្រោង | ៥៤៣៩៥-001 |
| ប្រទេស | ប្រទេសកម្ពុជា |
| ធាតុចេញទី២ | បានបង្កើតមេរៀនសម្រាប់ការរៀនតាមប្រព័ន្ធអេឡិចត្រូនិក |
| ព្រឹត្តិការណ៍សំខាន់ទី១ | សេចក្តីព្រាងមាតិកាវគ្គសិក្សា |
| ព្រឹត្តិការណ៍សំខាន់ទី២ | សេចក្តីព្រាងវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| ព្រឹត្តិការណ៍សំខាន់ទី៣ | ការដំណើរការ និងសាកល្បងវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| ព្រឹត្តិការណ៍សំខាន់ទី៤ | ច្បាប់ស្ថាពរនៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| ព្រឹត្តិការណ៍សំខាន់ទី៥ | របាយការណ៍សង្ខេប ការធ្វើបទបង្ហាញ និងជំនួយបច្ចេកទេស |

# សេចក្តីផ្តើម

1. ត្រូវបានអនុម័តដោយការិយាល័យអគ្គទីប្រឹក្សាច្បាប់ (OGC) នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០។ យោងតាមអនុស្សរណៈនៃការអនុម័តជំនួយបច្ចេកទេសសម្រាប់ការគាំទ្រ និងចំណេះដឹងខ្នាតតូច (SSTA) វត្ថុបំណងរបស់ TA គឺ ដើម្បីពង្រឹងចំណេះដឹង និងជំនាញស្តីពីក្របខណ្ឌច្បាប់ និងនិយ័តកម្មថ្នាក់ជាតិ និងតំបន់ សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក ADB (DMCs) ដែលត្រូវបានជ្រើសរើស ដើម្បីផ្តល់ការកសាងសមត្ថភាពដល់វិស័យឯកជន និងមន្ត្រីរដ្ឋាភិបាល និងលើកកម្ពស់កិច្ចសន្ទនាអំពីគោលនយោបាយ ដើម្បីអនុញ្ញាតឲ្យមានការពង្រីកសេដ្ឋកិច្ចឌីជីថល។[1]

2. លទ្ធផលដែលបានគ្រោងទុកនៃ "ការបង្កើនការចែករំលែកចំណេះដឹង និងលំហូរព័ត៌មាន ពាក់ព័ន្ធនឹងក្របខណ្ឌច្បាប់ ដែលគ្រប់គ្រងលើប្រតិបត្តិការអេឡិចត្រូនិក នៅក្នុង DMCs ដែលចូលរួម"[2] នឹងសម្រេចបានតាមរយៈការកសាងសមត្ថភាពដល់វិស័យឯកជន និងមន្ត្រីរដ្ឋាភិបាល ស្តីពីអនុសញ្ញាអន្តរជាតិ និងសន្ធិសញ្ញាទ្វេភាគី ពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ជាតិដែលពាក់ព័ន្ធ និងរបៀបដំណើរការអនុសញ្ញា សន្ធិសញ្ញា និងច្បាប់ទាំងនោះតាមគោលបំណង ដោយផ្តោតលើទស្សនៈអាជីវកម្ម ព្រមទាំងការអនុវត្តល្អបំផុត ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិផងដែរ។[3]

3. TA មានធាតុចេញចំនួនបី របាយការណ៍បច្ចុប្បន្នពាក់ព័ន្ធនឹង*ធាតុចេញទី២៖ បង្កើតមេរៀនសម្រាប់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក*។ កិច្ចការសម្រាប់*ធាតុចេញទី២* ដូចបានឯកភាពគ្នាតាមរយៈ MOU រវាង ADB និងក្រសួងពាណិជ្ជកម្ម (MoC) នៃប្រទេសកម្ពុជា ត្រូវបានកំណត់ថាជា៖
ការវាយតម្លៃតម្រូវការ និងការបង្កើតវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក៖
   - លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីអក្ខរកម្មឌីជីថល ជាពិសេស ការកសាងអក្ខរកម្មឌីជីថលអំពីអាជីវកម្មអំណោយផល
   - កសាងជំនាញស្តីពីបរិវត្តកម្មឌីជីថលដល់មន្ត្រីរដ្ឋាភិបាល ដើម្បីដោះស្រាយពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុង និងក្រៅប្រទេសបានកាន់តែល្អប្រសើរ
   - បណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាលដែលទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

   បង្កើត និងផ្សព្វផ្សាយសម្ភារៈបណ្តុះបណ្តាល និងធនធានចំណេះដឹងតាមតំបន់ និងប្រទេស។

4. ក្របខណ្ឌនៃការរចនា និងការត្រួតពិនិត្យ ដែលភ្ជាប់មកជាមួយនឹង SSTA ផ្តល់ជូននូវសូចនាករសមិទ្ធកម្មដូចខាងក្រោម និងយន្តការរាយការណ៍ដែលពាក់ព័ន្ធ សម្រាប់ធាតុចេញទី២៖[4]

---

[1] ការិយាល័យអគ្គទីប្រឹក្សាច្បាប់នៃ ADB អនុស្សរណៈស្តីពីជំនួយបច្ចេកទេសសម្រាប់ការគាំទ្រ និងចំណេះដឹងខ្នាតតូច (នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០) ប្រការ ២.

[2] Ibid ប្រការ ៨.

[3] Ibid ប្រការ ៧.

[4] អនុស្សរណៈនៃការអនុម័តជំនួយបច្ចេកទេសសម្រាប់ការគាំទ្រ និងចំណេះដឹងខ្នាតតូច ឧបសម្ព័ន្ធទី២.

| សូចនាករសមិទ្ធកម្មរួមជាមួយគោលដៅ និងខ្សែបន្ទាត់គោល | ធនធានទិន្នន័យ និងយន្តការរាយការណ៍ |
|---|---|
| ២ក. វគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក តាមប្រព័ន្ធពហុផ្សព្វផ្សាយ យ៉ាងតិចមួយ ត្រូវបានបង្កើតឡើង និងផ្តល់ជូន និងមានអ្នកចូលរួមយ៉ាងតិច ៥0 នាក់ទទួលបានវិញ្ញាបនបត្រពីវគ្គសិក្សាអនឡាញ។ | ២ក. របាយការណ៍ស្តីពីវឌ្ឍនភាពរបស់ TA និងរបាយការណ៍របស់ទីប្រឹក្សា |
| ២ខ. អ្នកចូលរួមយ៉ាងតិច ៥0% បានប្រឡងជាប់ការវាយតម្លៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។ | ២ខ. វិញ្ញាបនបត្រវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ការបញ្ចប់កិច្ចការនៃព្រឹត្តិការណ៍សំខាន់ទី១ |

5. សកម្មភាពគន្លឹះសម្រាប់ទីប្រឹក្សា ដែលបានចូលរួមសម្រាប់ធាតុចេញទី២ ត្រូវបានកំណត់ថាមាន៖
   - ធ្វើការវាយតម្លៃអំពីតម្រូវការ និងបង្កើតវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក
   - បង្កើត និងផ្សព្វផ្សាយធនធានឧបទ្ទេស សម្ភារបណ្តុះបណ្តាល និងធនធានចំណេះដឹងតាមតំបន់ និងតាមប្រទេសជាក់លាក់ ដោយផ្អែកលើការវាយតម្លៃអំពីតម្រូវការ និងមតិត្រឡប់ពីភាគីពាក់ព័ន្ធ។[5]

6. TA ត្រូវបានបំពេញជាប្រាំដំណាក់កាលដាច់ដោយឡែកពីគ្នា ដែលត្រូវបានកំណត់ថាជាព្រឹត្តិការណ៍សំខាន់ នៅក្នុងលក្ខខណ្ឌយោងដូចខាងក្រោម៖

7. ព្រឹត្តិការណ៍សំខាន់ទី១៖ សេចក្តីព្រាងមាតិកាវគ្គសិក្សា

ធ្វើការស្រាវជ្រាវ និងវាយតម្លៃអំពីតម្រូវការ

ការដាក់ជូន និងការទទួលយកដោយ DMC និង ADB នូវសេចក្តីព្រាងមាតិកាវគ្គសិក្សា

បន្ទាប់ពីបានប្រឹក្សាយោបល់ជាមួយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ កំណត់អត្តសញ្ញាណអ្នកទទួលផលនៃសម្ភារសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងការវាយតម្លៃអំពីតម្រូវការ ដាក់ជូនសេចក្តីព្រាងមាតិកាវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដែលចង្អុលបង្ហាញអំពីអភិក្រម និងវិធីសាស្ត្ររបស់អ្នកប្រឹក្សាយោបល់ វត្ថុបំណងនៃការសិក្សា និងខ្លឹមសារទូទៅអំពីមេរៀន និងរបៀបធ្វើបទបង្ហាញនៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។[6]

ការរៀបចំវែបសាយត៍របស់ TA

[5] Ibid.

[6] ADB TA-៦៦១៨ REG៖ ការបង្កើតបរិយាកាសអំណោយផលសម្រាប់សេដ្ឋកិច្ចឌីជីថល - អ្នកប្រឹក្សាយោបល់អំពីការបង្កើតវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (CAM) (៥៤៣៩៥-00១) លក្ខខណ្ឌយោង។

ផ្តល់ការគាំទ្រដល់អ្នកប្រឹក្សាយោបល់នៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកអន្តរជាតិ ក្នុងការប្រឹក្សាយោបល់ជាមួយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ កំណត់អត្តសញ្ញាណអ្នកទទួលផលនៃសម្ភារសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងការវាយតម្លៃអំពីតម្រូវការ និងការធ្វើសេចក្តីព្រាងមាតិកាវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដែលចង្អុលបង្ហាញអំពីអភិក្រម និងវិធីសាស្ត្ររបស់អ្នកប្រឹក្សាយោបល់ វត្ថុបំណងនៃការសិក្សា និងខ្លឹមសារទូទៅអំពីមេរៀន និងរបៀបធ្វើបទបង្ហាញនៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។[7]

8. ព្រឹត្តិការណ៍សំខាន់ទី២៖ សេចក្តីព្រាងវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការដាក់ជូន និងការទទួលយកដោយ DMC និង ADB នូវសេចក្តីព្រាងវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

- ដាក់ជូនសេចក្តីព្រាងមេរៀននៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបំពេញដោយខ្លឹមសារមេរៀន វីដេអូ គំនូរជីវចល កម្រងសំណួរការស្ទង់មតិ/មតិត្រឡប់ និងត្រៀមខ្លួនជាស្រេចសម្រាប់ការធ្វើតេស្តអ្នកសិក្សា។[8]
- ផ្តល់ការគាំទ្រដល់អ្នកប្រឹក្សាយោបល់នៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកអន្តរជាតិ ក្នុងការធ្វើសេចក្តីព្រាងមេរៀននៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបំពេញដោយខ្លឹមសារមេរៀន វីដេអូ គំនូរជីវចល កម្រងសំណួរការស្ទង់មតិ/មតិត្រឡប់ និងត្រៀមខ្លួនជាស្រេចសម្រាប់ការធ្វើតេស្តអ្នកសិក្សា។[9]

9. ព្រឹត្តិការណ៍សំខាន់ទី៣៖ ការដំណើរការ និងវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលបានធ្វើតេស្តសាកល្បងរួច

ការធ្វើតេស្តសាកល្បងដោយអ្នកចូលរួម និងការប្រមូលមតិត្រឡប់ស្តីពីវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក

ការធ្វើតេស្តសាកល្បងមេរៀននៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដោយអ្នកសិក្សានាពេលអនាគត និងទទួលបានមតិត្រឡប់ពីរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ[10]

[7] ADB TA-៦៦១៨ REG៖ ការបង្កើតបរិយាកាសអំណោយផលសម្រាប់សេដ្ឋកិច្ចឌីជីថល - អ្នកប្រឹក្សាយោបល់អំពីការបង្កើតវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (CAM) (៥៤៣៩៥-០០១) លក្ខខណ្ឌយោង។

[8] TR អ្នកប្រឹក្សាយោបល់អន្តរជាតិ កំណត់សម្គាល់ខាងលើទី៦។

[9] TR អ្នកប្រឹក្សាយោបល់ជាតិ កំណត់សម្គាល់ខាងលើទី៧។

[10] TR អ្នកប្រឹក្សាយោបល់អន្តរជាតិ កំណត់សម្គាល់ខាងលើទី៦។

ផ្តល់ការគាំទ្រដល់អ្នកប្រឹក្សាយោបល់នៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកអន្តរជាតិ ក្នុងការធ្វើតេស្តសាកល្បងមេរៀននៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដោយអ្នកសិក្សានាពេលអនាគត និងទទួលបានមតិត្រឡប់ពីរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ។[11]

10. ព្រឹត្តិការណ៍សំខាន់ទី៤៖ វគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកស្ថាពរ

ការដាក់ជូន និងការទទួលយកដោយ DMC និង ADB នូវវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកស្ថាពរ

ដោយផ្អែកលើមតិត្រឡប់របស់អ្នកសិក្សានាពេលអនាគត និងភាគីពាក់ព័ន្ធ កែសម្រួលមាតិកាវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការដាក់ឱ្យប្រើប្រាស់ជាស្ថាពរនៃមេរៀន រួមជាមួយការចេញវិញ្ញាបនបត្របញ្ចប់ការសិក្សា

ការបកប្រែសម្ភារ និងផលិតផលចំណេះដឹងដទៃទៀត ជាភាសាមូលដ្ឋាន

ដោយផ្អែកលើមតិត្រឡប់របស់អ្នកសិក្សានាពេលអនាគត និងភាគីពាក់ព័ន្ធ ផ្តល់ការគាំទ្រដល់ទីប្រឹក្សាវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកអន្តរជាតិក្នុងការកែសម្រួលមាតិកាវគ្គសិក្សាតាមអេឡិចត្រូនិកសម្រាប់ការដាក់ឱ្យប្រើប្រាស់ជាស្ថាពរនៃមេរៀននានា រួមជាមួយការចេញវិញ្ញាបនបត្របញ្ចប់ការសិក្សា។

11. ព្រឹត្តិការណ៍សំខាន់ទី៥៖ របាយការណ៍សង្ខេប បទបង្ហាញ និងជំនួយបច្ចេកទេស

ការដាក់ជូនរបាយការណ៍សង្ខេបស្តីពីដំណើរការវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ការធ្វើបទបង្ហាញ (បើមាន) និងជំនួយបច្ចេកទេស

ដាក់ជូនរបាយការណ៍ស្តីពីមេរៀននៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក រួមជាមួយស្ថិតិអ្នកចូលរួម ស្របតាមក្របខណ្ឌការរចនា និងត្រួតពិនិត្យជំនួយបច្ចេកទេស និងផ្តល់ការគាំទ្រចំពោះបញ្ហាបច្ចេកទេសដែលអ្នកសិក្សាអាចជួបប្រទះ។ ប្រសិនបើមាន ធ្វើបទបង្ហាញ និងផ្សព្វផ្សាយអំពីវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងរបកគំហើញនៅក្នុងព្រឹត្តិការណ៍/វេទិកានានា។

ពហុប្រព័ន្ធផ្សព្វផ្សាយ វេបសាយ៍ និងជំនួយផ្នែកព័ត៌មានវិទ្យា

របាយការណ៍អំពីការប្រើប្រាស់ និងការវិភាគអំពីវេបសាយត៍

ផ្តល់ការគាំទ្រដល់ទីប្រឹក្សាវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកអន្តរជាតិចំពោះមេរៀននៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក រួមជាមួយស្ថិតិអ្នកចូលរួម ស្របតាមក្របខណ្ឌការរចនា និងត្រួតពិនិត្យជំនួយបច្ចេកទេស និងផ្តល់ការគាំទ្រចំពោះបញ្ហាបច្ចេកទេសដែលអ្នកសិក្សាអាច

[11] TR អ្នកប្រឹក្សាយោបល់ជាតិ កំណត់សម្គាល់ទី៧ខាងលើ។

ជួបប្រទះ។ ប្រសិនបើមាន ធ្វើបទបង្ហាញ និងផ្សព្វផ្សាយអំពីវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងរបកគំហើញនៅក្នុងព្រឹត្តិការណ៍/វេទិកានានា។

ឯកសារបច្ចុប្បន្នគឺជារបាយការណ៍សង្ខេប ដែលត្រូវបានតម្រូវសម្រាប់ព្រឹត្តិការណ៍សំខាន់ទី៥ ដែលរួមមានសេចក្តីពណ៌នា និងធាតុចេញនៃព្រឹត្តិការណ៍សំខាន់នីមួយៗកាលពីមុន ដែលនាំឲ្យឈានដល់ការបញ្ចប់ធាតុចេញទី២ នៃ TA។

## ព្រឹត្តិការណ៍សំខាន់ទី១

12. ចំពោះសមាសធាតុការវាយតម្លៃអំពីតម្រូវការ អ្នកប្រឹក្សាយោបល់បានបង្កើតកម្រងសំណួរសម្រាប់ MoC ដើម្បីជួយកំណត់តម្រូវការ និងការរំពឹងទុករបស់អ្នកទទួលផល TA យ៉ាងលម្អិតពេញលេញ (ឧបសម្ព័ន្ធទី១)។ សំណួររួមមាន ការស្រាយបំភ្លឺ ដែលចាំបាច់ដើម្បីកំណត់កិច្ចការជាក់លាក់របស់អ្នកប្រឹក្សាយោបល់ និងការរំពឹងទុករបស់អ្នកទទួលផល ដែលរងផលជះពី៖

- វិសាលភាព និងរចនាសម្ព័ន្ធនៃវគ្គសិក្សា ដែលបានរំពឹងទុក – ដែលរួមមាន លទ្ធផលសិក្សាជាក់លាក់ វិធីសាស្ត្របង្រៀនដែលចង់ប្រើ កម្រិត រយៈពេល និងការវាយតម្លៃ
- អ្នកប្រើប្រាស់គោលដៅ – ដែលរួមមាន ចំណេះដឹងដែលត្រូវបានសន្មត អំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សមត្ថភាពផ្នែកបច្ចេកទេស និងភាសា
- ក្របខណ្ឌដែលវគ្គសិក្សានឹងដំណើរការ – រួមទាំង វគ្គសិក្សាដែលមានស្រាប់ដទៃទៀត ស្តីពីប្រធានបទ និងថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងៗ
- បរិយាកាសផ្នែកបច្ចេកទេស ដែលវគ្គសិក្សាត្រូវតែពិចារណា – ដែលរួមមាន ថ្នាល ដែលនឹងត្រូវរៀបចំវគ្គសិក្សា ថ្នាល ដែលវគ្គសិក្សាត្រូវតែរួមបញ្ចូលនៅក្នុងខ្លឹមសារមេរៀនដែលត្រូវរៀបរៀង និងដែនកំណត់ ដែលអ្នកប្រឹក្សាយោបល់ត្រូវពិចារណានៅពេលបង្កើតវគ្គសិក្សា។

13. កម្រងសំណួរត្រូវបានផ្តល់ជូនដោយ ADB ទៅកាន់ MoC នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២។ MoC បានបញ្ជូនកម្រងសំណួរទៅកាន់វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ (TTRI) ដោយចាត់តាំងវិទ្យាស្ថានជាស្ថាប័នពាក់ព័ន្ធក្នុងការទទួលបន្ទុកធាតុចេញទី២ នៃ TA។ TTRI បានផ្តល់ការឆ្លើយតប (ដែលបានរួមបញ្ចូលនៅក្នុងឧបសម្ព័ន្ធទី១ ផងដែរ) នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។ ចម្លើយទាំងនេះបានផ្តល់ចំណុចចាប់ផ្តើមសម្រាប់ការកំណត់ខ្លឹមសារសមស្រប និងរបៀបបង្រៀន និងវត្ថុបំណងគន្លឹះនៃការសិក្សា។

14. ខ្លឹមសារនៃវគ្គសិក្សាត្រូវបានដឹកនាំដោយវត្ថុបំណងគន្លឹះនៃការសិក្សា និងអ្នកប្រើប្រាស់គោលដៅ ដែលត្រូវបានកំណត់ដោយអ្នកទទួលផល និងអាចមានការកែប្រែបន្ទាប់ពីទទួលបានមតិត្រឡប់ចំពោះព្រឹត្តិការណ៍សំខាន់ទី១។ វគ្គសិក្សាត្រូវបានស្នើឱ្យមានមេរៀនចំនួនប្រាំមួយ ដែលមេរៀននីមួយៗគ្របដណ្តប់លើប្រធានបទចំនួនបួន។ មេរៀនចំនួនបីដំបូងត្រូវបានរៀបចំឡើងដើម្បីឱ្យ

ពាក់ព័ន្ធនឹងសិស្សគ្រប់ប្រភេទ នៅខណៈពេលដែលមេរៀនចំនួនបីផ្សេងទៀតគឺពាក់ព័ន្ធនឹងក្រុមគោលដៅជាក់លាក់។ ដោយសារវិសាលភាពនៃការគ្របដណ្តប់របស់មាតិកា សិស្សអាចជ្រើសរើសចំណុចបញ្ចប់នៃវគ្គសិក្សាខុសៗគ្នា ដោយមិនចាំបាច់បញ្ចប់គ្រប់មេរៀនទាំងអស់នោះទេ។ វិញ្ញាបនបត្របញ្ចប់ការសិក្សាត្រូវបានរៀបចំឡើងដើម្បីឆ្លុះបញ្ចាំងអំពីមេរៀនដែលបានបញ្ចប់ទៅតាមនោះ។

15. រចនាសម្ព័នដែលត្រូវបានស្នើឡើងនៅក្នុងព្រឹត្តិការណ៍សំខាន់ទី១ រួមមាន មេរៀនចំនួនប្រាំមួយដូចខាងក្រោម រួមជាមួយលក្ខខណ្ឌនៃការបញ្ចប់ ដែលត្រូវបានបញ្ជាក់សម្រាប់មេរៀនចំនួនបី៖

   មេរៀនទី១. សេចក្តីផ្តើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
   មេរៀនទី២. ក្របខណ្ឌនីតិបញ្ញត្តិ
   (ខ្លឹមសារមេរៀននេះ មួយផ្នែក នឹងទទួលបានពីធាតុចេញទី១ នៃ TA)
   មេរៀនទី៣. សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត
   មេរៀនទី៤. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមទស្សនៈរបស់អ្នកប្រើប្រាស់
   មេរៀនទី៥. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមទស្សនៈរបស់អាជីវកម្មខ្នាតតូច
   (ធនធានមួយចំនួន ចាំបាច់ត្រូវផ្តល់ជូនដោយ MoC)
   មេរៀនទី៦. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមទស្សនៈរបស់រដ្ឋាភិបាល
   (ខ្លឹមសារមេរៀននេះនឹងអាចស្វែងរកបានដោយ MoC)

16. មេរៀន និងប្រធានបទជាក់លាក់ត្រូវបានសម្គាល់ថា អាស្រ័យលើមតិត្រឡប់ដែលទទួលបានពី MoC មុនពេលបង្កើតមាតិកានៃវគ្គសិក្សា។ ប្រសិនបើត្រូវបានអនុម័ត ខ្លឹមសារសម្រាប់មេរៀនមួយចំនួន ចាំបាច់ត្រូវតែផ្តល់ជូនអ្នកប្រឹក្សាយោបល់ ដូចបានចង្អុលបង្ហាញនៅខាងលើ។

17. ពេលវេលាដែលចំណាយលើមេរៀននីមួយៗនឹងពឹងផ្អែកយ៉ាងទូលំទូលាយលើសាវតាចំណេះដឹងជំនាញដែលមានស្រាប់ ភាសា និងសមត្ថភាពសិក្សារបស់សិស្សម្នាក់ៗ។ ផ្អែកតាមបទពិសោធន៍កន្លងមក ពេលវេលាសិក្សាសម្រាប់មេរៀននីមួយៗត្រូវបានរៀបចំឡើងប្រហែលប្រាំម៉ោង រួមទាំងការបង្រៀនជាវីដេអូ និងធនធាននៃការអានផងដែរ។ ពេលវេលានេះក៏អាចរួមបញ្ចូលការបញ្ចប់សំណួរធ្វើតេស្តលើកដំបូង និងលើកចុងក្រោយផងដែរ ប៉ុន្តែមិនរួមបញ្ចូលលំហាត់ជាក់ស្តែង ដែលជាការវាយតម្លៃលើកចុងក្រោយសម្រាប់មេរៀននោះទេ។ លំហាត់ជាក់ស្តែងអាចចំណាយពេលពីកន្លះម៉ោងទៅមួយម៉ោង អាស្រ័យលើកម្រិតនៃការត្រៀមខ្លួនរបស់សិស្ស និងការជួបប្រទះកាលពីមុនចំពោះថ្នាល ដែលបានឆ្លុះបញ្ចាំងនៅក្នុងការវាយតម្លៃ។ ដូច្នេះ ពេលវេលាសិក្សាសរុបសម្រាប់មេរៀនទាំងប្រាំមួយត្រូវបានរំពឹងថានឹងមានចំនួនប្រហែល ៣០ ម៉ោង បូកបញ្ចូលរយៈពេលរហូតដល់ប្រាំមួយម៉ោងសម្រាប់ការធ្វើលំហាត់ជាក់ស្តែងផងដែរ។

18. លទ្ធផលសិក្សា ដែលត្រូវបានស្នើសម្រាប់វគ្គសិក្សានេះ ត្រូវបានកំណត់ដូចតទៅ៖

   ស្វែងយល់អំពីទស្សនាទាន និងពាក្យបច្ចេកទេសនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គំរូអាជីវកម្ម និងលក្ខខណ្ឌតម្រូវផ្នែកបច្ចេកវិទ្យាមូលដ្ឋាន

ស្វែងយល់ និងប្រើប្រាស់ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេសកម្ពុជា និងក្របខណ្ឌអន្តរជាតិ

បង្កើត និងដំណើរការ និង/ឬចុះបញ្ជីអាជីវកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេសកម្ពុជា

បង្កើតការអនុវត្តល្អបំផុត ក្នុងការប្រើប្រាស់ និង/ឬធ្វើនិយ័តកម្ម និងគ្រប់គ្រងថ្នាលឌីជីថល។

19. ប្រភេទមាតិកាឌីជីថល ដែលពាក់ព័ន្ធនឹងការបង្កើតវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានកំណត់ជា ឯកសារ PDF បទបង្ហាញ PowerPoint ឯកសារ MS Word - រាល់ឯកសារស្តង់ដារសម្រាប់ផ្តល់ការបណ្តុះបណ្តាលណាមួយ។ លើសពីនេះទៀត នៅក្នុងមេរៀននីមួយៗ មានការយល់ព្រមរួមបញ្ចូលវីដេអូខ្លីៗ ដោយប្រើវត្ថុមានចលនា ឬមនុស្សម្នាក់ ដែលពន្យល់អំពីទស្សនាទានសំខាន់ៗ និង/ឬបង្ហាញកិច្ចការអនឡាញនៅក្នុងបរិយាកាសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ចំពោះមេរៀនដែលមាននិរន្តរភាព និងអាចប្រើប្រាស់បានក្នុងរយៈពេលវែងសម្រាប់សិស្សនាពេលអនាគត ដោយមិនចាំបាច់មានការចូលរួមក្នុងការសិក្សាដែលមានតម្លៃថ្លៃនោះ ទាំងការសិក្សា និងការវាយតម្លៃចាំបាច់ត្រូវដំណើរការដោយស្វ័យប្រវត្តិទាំងស្រុង។ ការសិក្សាប្រភេទនេះពឹងផ្អែក និងអាស្រ័យលើវិន័យ និងការលើកទឹកចិត្តខ្លួនឯងរបស់សិស្ស ដែលអាចសន្មតថាមាននៅក្នុងប្រភេទនៃការអប់រំសម្រាប់មនុស្សពេញវ័យ ផ្នែកអភិវឌ្ឍន៍ខ្លួនឯង និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជាវិស័យដែលវគ្គសិក្សានេះនឹងកំណត់គោលដៅលើ ជាដើម។ ខ្លឹមសារសម្រាប់មេរៀននៃការសិក្សានេះអាចចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់ រួមជាមួយការធ្វើវិសោធនកម្មច្បាប់ ឬការប្រែប្រួលនៅលើថ្នាលនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងរដ្ឋាភិបាល។ ទោះបីជាយ៉ាងណាក៏ដោយ ជំនាញដែលវគ្គសិក្សាផ្តល់ជូនគួរតែអាចផ្ទេរបាន ធ្វើដូច្នេះ សិស្សអាចសម្របខ្លួនទៅនឹងការប្រែប្រួលបែបនេះបានយ៉ាងងាយស្រួល ដោយមិនចាំបាច់ចូលរួមវគ្គសិក្សាម្តងទៀតឡើយ។ នាយកដ្ឋានរដ្ឋាភិបាលអាចជ្រើសរើស តម្រូវឱ្យបញ្ចប់មេរៀនដែលបានធ្វើបច្ចុប្បន្នភាពបង្កើតនិយោជិតរបស់ពួកគេជាការអភិវឌ្ឍន៍វិជ្ជាជីវៈចាំបាច់ជាបន្តបន្ទាប់ (CPD) ដើម្បីធានាបាននូវការយល់ដឹងថ្មីៗរបស់ពួកគេអំពីក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ។

20. មាតិកានៃវគ្គសិក្សានេះត្រូវបានផ្តល់ជូនដើម្បីរួមបញ្ចូលសំណួរធ្វើតេស្ត និងអាចជាការប្រឡងអនឡាញ ដើម្បីធ្វើការវាយតម្លៃ អាស្រ័យលើសមត្ថភាពនៃប្រព័ន្ធសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងលក្ខខណ្ឌតម្រូវនៃការបញ្ជាក់របស់អ្នកទទួលផល។ ការវាយតម្លៃ ដែលត្រូវបានស្នើឡើងជាលើកដំបូង រួមមាន សំណួរធ្វើតេស្តបឋម សំណួរធ្វើតេស្តលើកចុងក្រោយ និងលំហាត់ជាក់ស្តែងសម្រាប់មេរៀននីមួយៗ។ តម្រូវការច្បាស់លាស់ក្នុងការកំណត់ថ្នាលដំណើរការ បានលេចឡើងដើម្បីសម្រេចចិត្តថាតើមាតិកា និងការវាយតម្លៃប្រភេទណា ដែលថ្នាលនេះអាចទទួលបន្ទុកបាន។ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍សំខាន់ទី១ ការវាយតម្លៃត្រូវបានរៀបចំឡើងតាមលំដាប់លំដោយពីមួយទៅមួយ។ អភិក្រមនេះប្រើគុណតម្លៃនៃបទពិសោធន៍ដើម្បីផ្តល់ជូនសិស្សនូវការទទួលស្គាល់ និងពង្រឹងចំណេះដឹងដែលមានស្រាប់ និងសាវតាររបស់ពួកគេ។ សំណួរធ្វើតេស្តលើកដំបូង ធ្វើតេស្ត

ចំណេះដឹងរបស់សិស្សដែលមានស្រាប់ កំណត់ភាពខ្លាំងដែលសិស្សអាចពង្រឹងបន្ថែមបាន នៅខណៈពេលនោះ កំណត់ផ្នែកដែលត្រូវអភិវឌ្ឍផងដែរ។ សិស្សអាចចូលប្រើប្រាស់មាតិកាមេរៀនបាន លុះត្រាតែសិស្សបានបញ្ចប់សំណួរធ្វើតេស្តលើកដំបូង។ សំណួរធ្វើតេស្តលើកទីពីរវាយតម្លៃការយល់ដឹងរបស់សិស្ស បន្ទាប់ពីបានបញ្ចប់ការបង្រៀនមួយមេរៀន។ ប្រសិនបើសិស្សរកឃើញចន្លោះប្រហោងនៅក្នុងចំណេះដឹងរបស់ពួកគេនោះ ពួកគេអាចពិនិត្យឡើងវិញលើផ្នែកពាក់ព័ន្ធនៃមេរៀននោះ ដើម្បីធានាបាននូវការយល់ដឹងយ៉ាងពេញលេញ។

21. នៅពេលដែលសមាសធាតុទ្រឹស្តីនេះត្រូវបានបញ្ចប់ ហើយសិស្សបានបញ្ចប់សំណួរធ្វើតេស្តលើកទីពីររួចរាល់ហើយនោះ សិស្សអាចបន្តការអនុវត្តជាក់ស្តែងនូវចំណេះដឹងដែលបានបង្ករ អនុវត្តទ្រឹស្តីក្នុងការអនុវត្ត និងអភិវឌ្ឍ ឬពង្រឹងជំនាញជាក់ស្តែង ដែលពាក់ព័ន្ធសម្រាប់វិស័យនោះ។ ការអនុវត្តជាក់ស្តែងនេះធានាថា សិស្សនឹងអភិវឌ្ឍជំនាញ ដែលចាំបាច់សម្រាប់ការងារនៅក្នុងជីវិតពិត នៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយគ្មានហានិភ័យនៃការទទួលរងផលវិបាកពីកំហុសឆ្គងលើកដំបូងនៅក្នុងជីវិតពិត។ លំហាត់ជាក់ស្តែងក៏ជាការវាយតម្លៃលើកចុងក្រោយសម្រាប់មេរៀននេះដែរ និងចាំបាច់ ដើម្បីទទួលបានវិញ្ញាបនបត្របញ្ចប់ការសិក្សា។ រួមជាមួយការបញ្ចប់លំហាត់ជាក់ស្តែងដោយជោគជ័យនោះ សិស្សអាចទទួលបានវិញ្ញាបនបត្រសម្រាប់មេរៀននោះ។

22. អ្នកទទួលផលបានស្នើសុំវិញ្ញាបនបត្រដែលចេញតាមប្រព័ន្ធឌីជីថល ដើម្បីផ្តល់ជូនដល់អ្នកដែលបានបញ្ចប់វគ្គសិក្សាដោយជោគជ័យ។ នេះអាចត្រូវបានដោះស្រាយនៅក្រៅថ្នាលនៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក លើកលែងតែត្រូវបានតម្រូវឱ្យចេញជាលក្ខណៈស្វ័យប្រវត្តិ។ អាស្រ័យលើប្រព័ន្ធដែលបានប្រើប្រាស់ វិញ្ញាបនបត្រស្វ័យប្រវត្តិក៏អាចត្រូវបានបង្កើតឡើងផងដែរ។

23. វគ្គសិក្សានេះត្រូវបានរំពឹងថានឹងប្រើទម្រង់មតិត្រឡប់អនឡាញ ដែលនឹងត្រូវបំពេញនៅពេលបញ្ចប់វគ្គសិក្សា។ ទ្រង់ទ្រាយនៃទម្រង់មតិត្រឡប់នេះពឹងផ្អែកយ៉ាងខ្លាំងលើប្រព័ន្ធដែលត្រូវប្រើដើម្បីដំណើរការវគ្គសិក្សានេះ ប៉ុន្តែទម្រង់នេះក៏អាចបង្កើតនៅលើថ្នាលឯករាជ្យមួយ (ដូចជា surveymonkee) ឬអាចរៀបចំជាទម្រង់ Google អនឡាញបានដែរ។

24. ទោះបីជាផ្អែកតាមទស្សនៈបច្ចេកទេស "ការរៀបចំវែបសាយត៍ TA" គឺជាកិច្ចការដំបូងសម្រាប់ព្រឹត្តិការណ៍សំខាន់ទី១ក៏ដោយ ដោយមានភាពយឺតយ៉ាវក្នុងការសម្រេចចិត្តអំពីថ្នាលនេះ អ្នកប្រឹក្សាយោបល់អាចចាប់ផ្តើមផលិតមាតិកាបានភ្លាមៗ បន្ទាប់ពីមានការបញ្ជាក់យល់ព្រមលើមេរៀននៃវគ្គសិក្សា។ ការធ្វើតេស្ត និងការផ្តល់វគ្គសិក្សា អាស្រ័យលើការកំណត់ថ្នាលដំណើរការ និងបរិមាណបន្ទុក និងដែនកំណត់របស់ថ្នាលនោះ អាស្រ័យហេតុនេះ កិច្ចការនេះត្រូវពន្យារពេលទៅដំណាក់កាលបន្ទាប់។

25. ព្រឹត្តិការណ៍សំខាន់ទី១ ត្រូវបានបញ្ចប់ត្រឹមថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២២ ត្រូវបានរាយការណ៍ទៅកាន់ និងអនុម័តដោយអ្នកទទួលផល MoC វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ (TTRI) នៅក្នុង MoC និងដោយ ADB។

# ព្រឹត្តិការណ៍សំខាន់ទី២

26. ព្រឹត្តិការណ៍សំខាន់ទី២ បានកំណត់ពេលវេលាជាលើកដំបូងថាបញ្ចប់នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២២ ដែលត្រូវបានពន្យារពេលជាច្រើនលើក។ ក្នុងអំឡុងពេលនេះ ការចូលប្រើប្រាស់ត្រូវបានស្នើសុំទៅកាន់ថ្នាលរបស់រដ្ឋាភិបាល ដែល MoC មានបំណងរួមបញ្ចូលនៅក្នុងវគ្គសិក្សានេះ ដើម្បីបង្កើតឯកសារបណ្តុះបណ្តាលគោលដៅ ព្រមទាំងព័ត៌មានអំពីដំណើរការផ្ទៃក្នុង និងលិខិតបទដ្ឋានគតិយុត្តិ ដែលនឹងអនុញ្ញាតឱ្យមានមេរៀនស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ស្របតាមទស្សនៈរបស់រដ្ឋាភិបាល។ អ្នកប្រឹក្សាយោបល់ក៏បានស្នើសុំចូលប្រើប្រាស់ថ្នាល ដែលនឹងដំណើរការវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។ ពុំមានធាតុចូលសំខាន់ៗណាមួយត្រូវបានទទួលនោះទេ ប៉ុន្តែនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ TTRI បានជូនដំណឹងទៅកាន់អ្នកប្រឹក្សាយោបល់ថា ពុំមានថ្នាលដំណើរការសម្រាប់វគ្គសិក្សានេះទេ។

27. បន្ទាប់ពីមានការស៊ើបអង្កេតយ៉ាងទូលំទូលាយ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ វិទ្យាស្ថាន ADB (ADBI) បានយល់ព្រមដំណើរការផលិតផលនៃធាតុចេញទី២ នៅលើថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ពួកគេ ដោយផ្អែកលើលក្ខខណ្ឌខាងក្រោម៖

- ប្រធានបទចាំបាច់ត្រូវធ្វើបទបង្ហាញនៅក្នុងបរិបទទូលំទូលាយ ដើម្បីផ្តល់គុណតម្លៃដល់ទូទាំងតំបន់ ដែល ADBI ផ្តល់សេវា
- បទបង្ហាញ និងការវាយតម្លៃចាំបាច់ត្រូវសមស្របនឹងរចនាសម្ព័ន្ធ ទម្រង់គំរូ និងគោលការណ៍ណែនាំនៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ ADBI
- វិញ្ញាបនបត្របញ្ចប់ការសិក្សា អាចស្វែងរកបានសម្រាប់ការបញ្ចប់វគ្គសិក្សាដោយជោគជ័យ មិនមែនសម្រាប់សមាសធាតុនៃវគ្គសិក្សានីមួយៗនោះទេ។

28. បន្ទាប់ពីទទួលបានគោលការណ៍ណែនាំស្តីពីការធ្វើបទបង្ហាញអំពីវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ ADBI មាតិកាដែលមានស្រាប់ត្រូវបានកែប្រែជាបណ្តើរៗ ដោយអ្នកប្រឹក្សាយោបល់របស់ ADB ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវរបស់ ADBI ចំពោះទម្រង់ និងការកត់ត្រា៖

- សម្ភារធ្វើបទបង្ហាញត្រូវបានផ្ទេរទៅក្នុងទម្រង់គំរូ power point របស់ ADBI និងបានរៀបចំឡើងវិញ ដើម្បីឱ្យសមស្របតាមទម្រង់ស្តង់ដារនៃវគ្គសិក្សា ADBI ទាំងអស់
- វីដេអូបង្រៀនត្រូវបានថតឡើងវិញ តាមរយៈ Power Point ដូចបានតម្រូវដោយ ADBI
- ស្ក្រីបត្រូវបានព្រាង ដើម្បីធ្វើជាមូលដ្ឋាននៃប្រតិចារឹក ដែលនឹងត្រូវផ្តល់ជូននៅលើថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ ADBI
- មគ្គុទ្ទេសក៍ណែនាំអំពីវគ្គសិក្សាត្រូវបានធ្វើសេចក្តីព្រាង ដោយផ្អែកលើទម្រង់គំរូរបស់ ADBI រួមទាំងលទ្ធផលសិក្សា ធនធាននៃការអាន និងសំណួរវាយតម្លៃផងដែរ

- សំណួរដើម្បីទទួលបានមតិត្រឡប់ត្រូវបានព្រាង ដើម្បីប្រមូលផ្តុំការវាយតម្លៃផ្នែកគុណវិស័យ និងបើកចំហរការទទួលយកមតិយោបល់ពីអ្នកចូលរួម។

29. មាតិកានៃវគ្គសិក្សានេះត្រូវបានកែសម្រួលតាំងពីព្រឹត្តិការណ៍សំខាន់ទី១ ដើម្បីសម្របទៅនឹងធនធានដែលអាចប្រើប្រាស់បានដោយសេរី ដើម្បីការចូលប្រើប្រាស់ដោយអ្នកប្រឹក្សាយោបល់ឯករាជ្យ។ ចំពោះមេរៀនទី២ ឯកសារដែលទទួលបានពីធាតុចេញទី១ នៃ TA បានចង្អុលបង្ហាញថា ពុំមានអត្ថបទច្បាប់ថ្មីៗនោះទេ ប៉ុន្តែមានសំណើដ៏មឹងម៉ាត់មួយ ក្នុងការធ្វើការឆ្ពោះទៅសម្រេចបាននូវក្រមសីលធម៌មួយសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេសកម្ពុជា។ អាស្រ័យហេតុនេះ មាតិកានៃក្របខណ្ឌច្បាប់នៅតែមិនផ្លាស់ប្តូរ ដោយរួមបញ្ចូលតែឯកសារយោងចំពោះអត្ថបទអន្តរជាតិ អត្ថបទថ្នាក់តំបន់ និងថ្នាក់ជាតិដែលមានស្រាប់ប៉ុណ្ណោះ។ ចំពោះមេរៀនទី៥ និងទី៦ ពុំមានធាតុចូលណាមួយត្រូវបានទទួលពី MoC នោះទេ។ មេរៀនទាំងនេះត្រូវបានកាត់បន្ថយមាតិកាទៅតាមនោះ។ ទោះបីជាយ៉ាងណាក៏ដោយ មាតិកាដែលត្រូវបានកែប្រែគឺ នៅតែស្របតាមការរំពឹងទុករបស់ MoC ដែលបានបង្ហាញនៅក្នុងដំណាក់កាលវាយតម្លៃអំពីតម្រូវការ ដើម្បីផ្តល់សេវាដល់អ្នកប្រើប្រាស់យ៉ាងទូលំទូលាយ រួមទាំង សាធារណជនទូទៅផងដែរ នៅខណៈពេលដែលរក្សាបាននូវមាតិកាដែលបម្រើដល់អាជីវកម្មកម្ពុជា។

30. រចនាសម្ព័ននៃវគ្គសិក្សានេះក៏ត្រូវបានផ្លាស់ប្តូរផងដែរ ដើម្បីឲ្យស្របនឹងថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ ADBI ដែលដំណើរការ។ ជាលទ្ធផល មេរៀនដែលបានស្នើឡើងកាលពីលើកដំបូងត្រូវបានផ្លាស់ថ្មីនៅក្នុងវគ្គសិក្សានីមួយៗ ដែលវគ្គសិក្សានីមួយៗបានរួមបញ្ចូលមេរៀន/ការបង្រៀនជាច្រើន ដែលត្រូវបានរៀបចំឡើងដើម្បីឱ្យសមស្របតាមពេលវេលា ដែលកំណត់ដោយគោលការណ៍ណែនាំរបស់ ADBI។ ជាលទ្ធផល រចនាសម្ព័ន្ធថ្មីនៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកទាំងបី និងលទ្ធផលសិក្សានៃវគ្គសិក្សាទាំងនោះ ត្រូវបានកំណត់ដូចខាងក្រោម៖

១. សេចក្តីផ្តើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

- ទស្សនាទានមូលដ្ឋាន
- បច្ចេកវិទ្យាដែលនៅពីក្រោយការធ្វើជំនួញ

លទ្ធផលសិក្សា៖

- យល់ដឹងអំពីទស្សនាទាន និងពាក្យបច្ចេកទេសនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ទទួលស្គាល់គំរូពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យល់ដឹងអំពីសមាសធាតុបច្ចេកវិទ្យាមូលដ្ឋាននៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យល់ដឹងអំពីមូលដ្ឋាននៃធនាគារអនឡាញ។

២. សិទ្ធិ និងកាតព្វកិច្ចនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

- សេចក្តីផ្តើមអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- សិទ្ធិ និងកាតព្វកិច្ចចំពោះអាជីវកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

- សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់

លទ្ធផលសិក្សា៖

- ការយល់ដឹងជាមូលដ្ឋានអំពីច្បាប់ជាតិ និងលិខិតូបករណ៍អន្តរជាតិ ដែលបង្កើតទ្រង់ទ្រាយលិខិតបទដ្ឋានគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាសកល និងនៅតំបន់អាស៊ីប៉ាស៊ីហ្វិក
- សិទ្ធិ និងកាតព្វកិច្ច ទាក់ទងនឹងការបង្កើត និងដំណើរការអាជីវកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈឧទាហរណ៍របស់ប្រទេសកម្ពុជា
- សុវត្ថិភាពអ្នកប្រើប្រាស់ សិទ្ធិ និងដំណោះស្រាយវិវាទនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៣. សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត

- ភាពពាក់ព័ន្ធនៃការការពារទិន្នន័យ
- ការទទួលស្គាល់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត
- ឧបករណ៍រក្សាសុវត្ថិភាពទិន្នន័យ។

លទ្ធផលសិក្សា៖

- យល់ដឹងអំពីហានិភ័យនៃការបញ្ជូនទិន្នន័យនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ទទួលស្គាល់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត និងការរំលោភបំពានលើទិន្នន័យ
- យល់ដឹងអំពីឧបករណ៍រក្សាសុវត្ថិភាពទិន្នន័យមូលដ្ឋាន និងរបៀបប្រើប្រាស់ឧបករណ៍ទាំងនោះ
- អាចឆ្លើយតប និងរៀនសូត្រពីហេតុការណ៍តាមប្រព័ន្ធអ៊ីនធឺណិត។

31. ការវាយតម្លៃក៏ត្រូវបានរៀបចំឡើងវិញផងដែរ ដើម្បីឱ្យសមស្របនឹងប្រព័ន្ធសិក្សាតាមអេឡិចត្រូនិករបស់ ADBI។ ជាលទ្ធផល វគ្គសិក្សានីមួយៗក្នុងចំណោមវគ្គសិក្សាទាំងបី មានការវាយតម្លៃចុងក្រោយតែមួយ ដែលមាននៅក្នុងសំណួរធ្វើតេស្ត ដែលរួមបញ្ចូលបណ្តុំសំណួរពហុជ្រើសរើស។ ការវាយតម្លៃអាចចូលប្រើប្រាស់បានលុះត្រាតែបានមើលការបង្រៀនដែលបានថតទុកជាមុនរួចរាល់ហើយ។ វិញ្ញាបនបត្របញ្ចប់ការសិក្សាត្រូវបានបង្កើតឡើងដើម្បីទាញយក សម្រាប់វគ្គសិក្សានីមួយៗដាច់ដោយឡែកពីគ្នា បន្ទាប់ពីបានបញ្ចប់សំណួរវាយតម្លៃដោយជោគជ័យ។

32. មាតិកាពេញលេញនៃវគ្គសិក្សាត្រូវបានផ្តល់ជូន ADB ADBI និងអ្នកទទួលផល MoC និង TTRI សម្រាប់ត្រួតពិនិត្យឡើងវិញ និងអនុម័ត នៅក្នុង Google drive រួមគ្នាមួយ។ មាតិកានៃវគ្គសិក្សានេះ (មិនរួមបញ្ចូលសំណួរ និងចម្លើយវាយតម្លៃ) ក៏បានភ្ជាប់មកជាមួយ ជាឧបសម្ព័ន្ធទី២ ផងដែរ។

33. ព្រឹត្តិការណ៍សំខាន់ទី២ ត្រូវបានបញ្ចប់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ត្រូវបានរាយការណ៍ទៅកាន់ និងអនុម័តដោយអ្នកទទួលផល MoC វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ (TTRI) នៅក្នុង MoC និងដោយ ADB។

# ព្រឹត្តិការណ៍សំខាន់ទី៣

34. ក្នុងអំឡុងព្រឹត្តិការណ៍សំខាន់ទី៣ មាតិកានៃវគ្គសិក្សាដែលត្រូវបានអនុម័ត ត្រូវបានអាប់ឡូតនៅក្នុងថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ ADBI និងត្រូវបានបញ្ចេញសម្រាប់ការធ្វើតេស្តនៅថ្ងៃទី០៩ ខែមិថុនា។ រូបថតស្គ្រីននៃទំព័រដាច់ដោយឡែកមួយនៃវគ្គសិក្សា ព្រមទាំងវិញ្ញាបនបត្របញ្ចប់ការសិក្សាអនឡាញ ត្រូវបានភ្ជាប់មកជាមួយ នៅក្នុងឧបសម្ព័ន្ធទី៣។

35. រាល់វគ្គសិក្សាដែលដំណើរការដោយ ADBI តម្រូវឱ្យបង្កើតគណនីបុគ្គលមួយ ដែលអាចដំឡើងបានដោយឥតគិតថ្លៃ។ លើសពីនេះទៀត វគ្គសិក្សាទាំងបីនេះត្រូវបានកំណត់ឱ្យមានការការពារដោយពាក្យសម្ងាត់បណ្តោះអាសន្ន និងអាចចូលប្រើបានតែចំពោះអ្នកដែលទទួលបានពាក្យសម្ងាត់នៅក្នុង TA នេះប៉ុណ្ណោះ ជាការរឹតបន្តឹង ដែលនឹងត្រូវលុបចេញបន្ទាប់ពីបានធ្វើតេស្តសាកល្បងរួចហើយ និងបន្ទាប់មក ការចេញផ្សាយលើកចុងក្រោយត្រូវបានបញ្ជាក់ថាបានបញ្ចប់ដោយជោគជ័យ។ អាស្រ័យហេតុនេះ ជំនួយបច្ចេកទេសត្រូវបានគ្រប់គ្រងដោយក្រុមការងារបច្ចេកទេស ADBI ដែលផ្តល់ជូនដូចខាងក្រោម (រួមជាមួយមាតិកាទាំងអស់ ដែលផ្តល់ជូនដោយអ្នកប្រឹក្សាយោបល់របស់ ADB)៖

- ត្រួតពិនិត្យឡើងវិញ និងធានាថា សម្ភារនៃវគ្គសិក្សាសមស្របតាមទម្រង់ដែលត្រូវបានតម្រូវ
- រៀបចំប្រតិចារិកពេញលេញចុងក្រោយ
- បង្កើតការវាយតម្លៃតាមអនឡាញ
- បង្កើតប្រព័ន្ធបញ្ជាក់តាមអនឡាញ
- បង្កើតទម្រង់មតិត្រឡប់តាមអនឡាញ
- អាប់ឡូតឯកសារនៃវគ្គសិក្សា និងប្រតិចារឹក ទៅក្នុងថ្នាលសិក្សាតាមប្រព័ន្ធអេឡិកត្រូនិករបស់ ADBI
- បង្កើតការចូលប្រើប្រាស់ ដែលការពារដោយពាក្យសម្ងាត់។

36. MoC បានផ្តល់បញ្ជីឈ្មោះបុគ្គល ៧៧ នាក់ ដែលត្រូវបញ្ចប់ការធ្វើតេស្តនៃវគ្គសិក្សានេះ។ ក្នុងចំណោមពួកគេ មានប្រាំនាក់មិនបានចុះបញ្ជីជាមួយ MoC ទេ ហើយអ្នកដទៃទៀតមកពី TTRI ឬនាយកដ្ឋានផ្សេងៗនៃ MoC។ មន្ត្រីទំនាក់ទំនងរបស់ MoC បានទទួលសំណុំការណែនាំលម្អិត រួមទាំងសេចក្តីរំពឹងទុកនៃវគ្គសិក្សា ព័ត៌មានលម្អិតអំពីការចូលប្រើប្រាស់ ការណែនាំអំពីការវាយតម្លៃ និងសំណើសុំឲ្យបំពេញទម្រង់មតិត្រឡប់តាមអនឡាញ នៅពេលដែលវគ្គសិក្សាត្រូវបានបញ្ចប់។

ទីប្រឹក្សាជាតិបានទំនាក់ទំនងជាមួយតំណាង MoC ដែលត្រូវបានចាត់តាំង ដើម្បីណែនាំអ្នកចូលរួមអំពីការបញ្ចប់វគ្គសិក្សា។

37. យោងតាមបញ្ជីនេះ របាយការណ៍ ADBI ដែលបានបង្កើតឡើងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ បានបង្ហាញថា ២១ នាក់មិនបានចុះឈ្មោះសម្រាប់ការអនុវត្តសាកល្បងនោះទេ។ បញ្ជីឈ្មោះអ្នកដែលបានចុះឈ្មោះសម្រាប់ដំណាក់កាលសាកល្បងនៃវគ្គសិក្សានេះ យោងតាមរបាយការណ៍ដែលផលិតឡើងដោយ ADBI ក៏ចង្អុលបង្ហាញអំពីស្ថានភាពបញ្ចប់ផងដែរ ដែលត្រូវបានភ្ជាប់មកជាមួយ ជាឧបសម្ព័ន្ធទី៤។ អត្រាបញ្ចប់ការសិក្សាជាមធ្យម ក្នុងចំណោមអ្នកចូលរួមដែលបានចុះឈ្មោះ នៅក្នុងវគ្គសិក្សាទាំងបីគឺ ៩៦,៤% ដូចខាងក្រោម៖

| វគ្គសិក្សា | ចំនួនអ្នកដែលបានចុះឈ្មោះ | ចំនួនអ្នកដែលបញ្ចប់ការសិក្សាដោយជោគជ័យ |
|---|---|---|
| សេចក្តីផ្តើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ៥៦ | ៥០ |
| សិទ្ធិ និងកាតព្វកិច្ចនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ៤៧ | ៤៧ |
| សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត | ៤៨ | ៤៨ |

38. ថ្នាលវគ្គសិក្សាតាមអនឡាញបានស្នើសុំឱ្យអ្នកចូលរួមផ្តល់មតិត្រឡប់លើវគ្គសិក្សាទាំងជាទម្រង់នៃការវាយតម្លៃចាប់ពីលេខ ១ ដល់ លេខ ៥ និងមតិយោបល់ជាអក្សរជាលក្ខណៈបើកចំហរ។ សំណួរសម្រាប់មតិត្រឡប់ត្រូវបានភ្ជាប់មកជាមួយ នៅក្នុងឧបសម្ព័ន្ធទី៥។

39. មតិត្រឡប់ត្រូវបានប្រមូលជារួមពីអ្នកចូលរួមចំនួន ៥០ នាក់ ដោយមានការវាយតម្លៃ និងមតិត្រឡប់សរុបចំនួន ៩៨ ត្រូវបានផ្តល់ជូនពីគ្រប់ទម្រង់មតិកែលម្អទាំងអស់។ មិនមានមតិត្រឡប់ត្រូវបានប្រមូលសម្រាប់សិទ្ធិ និងកាតព្វកិច្ចនៅក្នុងវគ្គសិក្សាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះទេ ដោយសារកំហុសដែលមិនអាចរកឃើញ នៅក្នុងការរៀបចំការអនុវត្តសាកល្បង ប៉ុន្តែការវាយតម្លៃដែលប្រមូលបានពីការធ្វើតេស្តសាកល្បងនៃវគ្គសិក្សាទាំងពីរត្រូវបានភ្ជាប់មកជាមួយ ជាឧបសម្ព័ន្ធទី៦។ មាត្រដ្ឋាននៃការចាត់ថ្នាក់ (ដែល ៥ គឺខ្ពស់បំផុត និង ១ គឺទាបបំផុត) នៅទូទាំងវគ្គសិក្សាទាំងបីគឺ៖

| ការចាត់ថ្នាក់ | ទិដ្ឋភាពដែលបានចាត់ថ្នាក់ | មាតិកានៃវគ្គសិក្សា | បទពិសោធន៍នៃការសិក្សា | ការវាយតម្លៃ |
|---|---|---|---|---|
| ៥ | | ៣៤% | ៣០% | ៤២% |
| ៤ | | ៥២% | ៤៧% | ៣៩% |
| ៣ | | ១២% | ២០% | ១៤% |
| ២ | | 0% | 0% | ២% |
| ១ | | ២% | ៣% | ៣% |

សម្គាល់៖ តម្លៃជាភាគរយត្រូវបានបង្គត់ចុះ ប្រសិនបើលទ្ធផលនៅខាងក្រោម ,៥ និងបង្គត់ឡើង ប្រសិនបើលទ្ធផលលើសពី ,៥។ ការបង្គត់ដូចគ្នាត្រូវបានអនុវត្តនៅក្នុងតារាងស្រដៀងគ្នានៅខាងក្រោម ជាបន្តបន្ទាប់ទៀត។

40. មតិយោបល់ជាលក្ខណៈបើកចំហ សរុបចំនួន ៨៥ ខុសៗគ្នា ត្រូវបានប្រមូលយក ដោយមិនរាប់បញ្ចូលមតិយោបល់ដែលចែងថា "គ្មានយោបល់" ឬមតិយោបល់បើកចំហដូចៗគ្នា នៅក្នុងទម្រង់មតិត្រឡប់លើសពីមួយ។ មតិយោបល់ទាំងនេះបានចង្អុលបង្ហាញអំពីសេចក្តីពេញចិត្តនៅកម្រិតខ្ពស់ និងការថ្លែងអំណរគុណជាទូទៅ រួមជាមួយមតិរិះគន់មានចំនួន ៧៣ ដែលមានប្រវែងខុសៗគ្នាអនុសាសន៍ដ៏មានតម្លៃមួយចំនួនតូច និងសង្កេតឃើញមានការរិះគន់តិចតួចបំផុត។ មតិយោបល់បើកចំហ ជាលក្ខណៈអនាមិក ត្រូវបានភ្ជាប់មកជាមួយ នៅក្នុងឧបសម្ព័ន្ធទី៧ ដែលមានកូដពណ៌សម្រាប់ភាពងាយស្រួលក្នុងការដំណើរការ។

41. មានមតិយោបល់ចំនួនបួន ទាក់ទងនឹងភាសា ដែលចង្អុលបង្ហាញថា ចំណេះដឹងភាសាអង់គ្លេសរបស់អ្នកចូលរួមគឺមិនគ្រប់គ្រាន់ក្នុងការស្វែងយល់យ៉ាងពេញលេញ ឬទទួលបានអត្ថប្រយោជន៍យ៉ាងពេញលេញពីវគ្គសិក្សានេះទេ។ មតិយោបល់មួយក្នុងចំណោមមតិយោបល់ទាំងនេះបានស្នើសុំឱ្យមានការបង្រៀនជាភាសាខ្មែរ និងមួយទៀតស្នើសុំឱ្យមានការបន្ថែមចំណងជើងរង។ មានមតិយោបល់ចំនួនប្រាំមួយពីអ្នកចូលរួមប្រាំនាក់ ដែលចង្អុលបង្ហាញថា ការមានថ្នាក់រៀនរូបវន្ត ឬវគ្គសិក្សាជាវីដេអូបន្តផ្ទាល់នឹងមានអត្ថប្រយោជន៍ ក្នុងការអនុញ្ញាតឱ្យមានការសួរសំណួរក្នុងអំឡុងពេលនៃវគ្គសិក្សា។ មតិមួយបានលើកឡើងថា ការមានវគ្គបន្តផ្ទាល់មួយសម្រាប់មេរៀននីមួយៗនឹងធ្វើឱ្យអ្នកចូលរួម ចូលរួមកាន់តែខ្លាំង និងរៀនសូត្របានកាន់តែប្រសើរ។ មតិបន្ថែមចំនួនប្រាំបីក៏បានបង្ហាញអំពីការចង់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះនាពេលអនាគតផងដែរ។ អ្នកធ្វើតេស្តសាកល្បងម្នាក់បានបញ្ចេញមតិចំនួនពីរ ទាក់ទងនឹងវិធីដែលការវាយតម្លៃត្រូវបានបង្កើតឡើង ដោយបញ្ជាក់ថា ការវាយតម្លៃ "ងាយស្រួលពេកសម្រាប់សិស្សក្នុងការធ្វើឡើងវិញ" និងថា ការវាយតម្លៃទាំងនោះអាច "ចម្លងពីចម្លើយត្រឹមត្រូវដែលត្រូវបានផ្តល់ជូន" ដែលធ្វើឱ្យសិស្ស "មិនរៀនសូត្របានច្រើននោះទេ"។ មានការសំណូមពរឲ្យសិស្ស "មើលវីដេអូម្តងហើយម្តងទៀត ដើម្បីរៀនសូត្របន្ថែម ដើម្បីឆ្លើយសំណួរឱ្យបានត្រឹមត្រូវ។ រាល់មតិយោបល់ទាំងអស់នេះត្រូវបានលើកឡើងមុនពេលបញ្ចប់វគ្គសិក្សាសម្រាប់ព្រឹត្តិការណ៍សំខាន់ទី៤ ដូចបានរាយការណ៍នៅក្នុងផ្នែកបន្ទាប់នៃរបាយការណ៍នេះ។

42. មានមតិបន្ថែមមួយចំនួន ទាក់ទងនឹងទិដ្ឋភាពផ្សេងៗនៃវគ្គសិក្សា ដែលមតិនីមួយៗត្រូវបានលើកឡើងនៅទីនេះ។ ការសង្កេតមួយបានលើកឡើងថា "វាពិតជាល្អណាស់ ប្រសិនបើមានវីដេអូបង្ហាញអំពីដំណើរការនៃប្រធានបទនីមួយៗ មិនមែនគ្រាន់តែពន្យល់អំពីប្រធានបទនោះទេ"។ គេមិនច្បាស់ថាតើអ្នកបញ្ចេញមតិ មានន័យយ៉ាងដូចម្តេចឲ្យពិតប្រាកដ ចំពោះមតិនេះទេ ប៉ុន្តែពួកគេប្រហែលជាសំដៅលើការមានវីដេអូគំនូរជីវចលនៅក្នុងការបង្រៀន។ នៅខណៈពេលដែលការរៀបចំវគ្គសិក្សាលើកដំបូងបានរួមបញ្ចូលគំនូរជីវចលបន្ថែមទៀត ដើម្បីបង្ហាញអំពីអ្វីដែលកំពុង

ពន្យល់នោះ អភិក្រមនេះត្រូវបានបោះបង់ចោល នៅពេលដែលការដំណើរការវគ្គសិក្សាត្រូវបានផ្លាស់ប្តូរទៅ ADBI។ ថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ ADBI តម្រូវឱ្យវគ្គសិក្សាទាំងអស់របស់ពួកគេអនុវត្តតាមគោលការណ៍ណែនាំដ៏តឹងរឹង ក្នុងការបង្កើតរូបរាងដូចៗគ្នា នៅគ្រប់វគ្គសិក្សាទាំងអស់ ដែលពួកគេដំណើរការ។ ការថតក៏ត្រូវបានតម្រូវឱ្យធ្វើឡើងតាមរយៈ Power Point នៅលើទម្រង់គំរូជាស្លាយដែលត្រូវបានផ្តល់ជូនផងដែរ។ ទាំងអស់នេះបានរឹតត្បិតលើលទ្ធភាពក្នុងការប្រើប្រាស់គំនូរជីវចលបន្តផ្ទាល់ ប៉ុន្តែស្លាយបានរួមបញ្ចូលរូបភាពតំណាង (គ្មានចលនា) ជាច្រើនសន្លឹក នៃអ្វីដែលត្រូវបានពន្យល់។

43. មតិមួយបានលើកឡើងថា មេរៀនវែង និង "អាចចំណាយពេលច្រើន"។ ប្រវែងមេរៀននីមួយៗមានភាពសមស្របតាមគោលការណ៍ណែនាំរបស់ ADBI។ ពេលវេលាដែលត្រូវចំណាយសម្រាប់មេរៀន គឺជាបញ្ហាមួយរបស់បុគ្គលម្នាក់ៗដែលកំពុងរៀនមេរៀននោះ ពីព្រោះពួកគេអាចឈប់ចាក់ឡើងវិញ មើល និងមើលឡើងវិញជាច្រើនដង តាមដែលពួកគេចង់ ឬត្រូវការមើលមេរៀននោះ។ ពុំមានការកំណត់ពេលវេលាសម្រាប់ក្រុមធ្វើតេស្តនោះទេ ហើយក៏ពុំមិនមានការកំណត់ពេលវេលាសម្រាប់អ្នកចូលរួមនាពេលអនាគតដែរ។

44. បន្ទាប់ពីបានប្រមូលផ្តុំមតិត្រឡប់ទាំងអស់ អ្នកប្រឹក្សាយោបល់បានស្នើឱ្យបន្តរក្សាមាតិកា និងទម្រង់នៃវគ្គសិក្សាដែលបានបង្កើតឡើង និងចាត់វិធានការដោះស្រាយមតិយោបល់ទាំងនោះ ដែលនឹងធ្វើឱ្យបទពិសោធន៍សិក្សាមានភាពល្អប្រសើរ ដូចបានរៀបរាប់ខាងក្រោម។ ព្រឹត្តិការណ៍សំខាន់ទី៣ ត្រូវបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។

# ព្រឹត្តិការណ៍សំខាន់ទី៤

45. សម្រាប់ព្រឹត្តិការណ៍សំខាន់ទី៤ អ្នកប្រឹក្សាយោបល់បានដោះស្រាយមតិត្រឡប់ ដែលទទួលបានក្នុងអំឡុងពេលអនុវត្តសាកល្បង។ ជាពិសេស ការបកប្រែជាភាសាខ្មែរត្រូវបានរៀបចំឡើងសម្រាប់ប្រតិចារិកពេញលេញនៃវគ្គសិក្សានីមួយៗ និងអាចស្វែងរកបាននៅលើថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ ADBI សម្រាប់ការបង្រៀននីមួយៗ ដែលបានថតទុក។ ការកំណត់ការវាយតម្លៃវគ្គសិក្សាក៏ត្រូវបានកែសម្រួលផងដែរ ដោយមិនបង្ហាញចម្លើយដែលត្រឹមត្រូវនោះទេ។

46. បន្ទាប់ពីមានការកែលម្អទាំងនេះ វគ្គសិក្សាត្រូវបានចាត់ទុកថាបានសម្រេចបញ្ចប់ និងត្រៀមជាស្រេចសម្រាប់ក្រុមថ្មី នៅក្នុងទម្រង់ដែលបានធ្វើបច្ចុប្បន្នភាពនេះ។ ដោយពិចារណាលើមតិត្រឡប់ដែលចង្អុលបង្ហាញអំពីការចង់ចូលរួមការបណ្តុះបណ្តាលដោយផ្ទាល់នោះ ក្រុមការងារ TA របស់ ADB អ្នកប្រឹក្សាយោបល់ថ្នាក់ជាតិ និងមន្ត្រីទំនាក់ទំនងរបស់ MOC បានរៀបចំវគ្គបណ្តុះបណ្តាលមួយថ្ងៃពេញ នៅភ្នំពេញ នៅថ្ងៃទី១៨ ខែសីហា។ ដោយមើលឃើញទម្រង់នៃវគ្គសិក្សាអនឡាញ

ដែលមានស្រាប់នោះ ថ្ងៃបណ្តុះបណ្តាលបានរួមបញ្ចូល ពេលវេលា ទីកន្លែង ម្ហូបអាហារ និងជំនួយបច្ចេកទេស ដែលត្រូវបានផ្តល់ជូនពេញមួយថ្ងៃ មិនមែនជាការបង្រៀនបន្តផ្ទាល់នោះទេ។

47. នៅក្នុងព្រឹត្តិការណ៍ដែលរៀបចំដោយផ្ទាល់ អ្នកចូលរួម ៥៤ នាក់បានចុះហត្ថលេខាបញ្ជាក់វត្តមាន (មិនរួមបញ្ចូលអ្នកផ្តល់ប្រឹក្សាយោបល់ថ្នាក់ជាតិ ដែលបានចូលរួម)។ របាយការណ៍ដែលទទួលបានពី ADBI បន្ទាប់ពីព្រឹត្តិការណ៍នោះ បានចង្អុលបង្ហាញថាមានចំនួនខ្ពស់ជាងមុនបន្តិច ដោយមានអ្នកចូលរួមបន្ថែមបានចុះឈ្មោះ និងបញ្ចប់វគ្គសិក្សា ក្រោយពេលធ្វើតេស្តសាកល្បង ប៉ុន្តែមិនបានចូលរួមក្នុងព្រឹត្តិការណ៍ដោយផ្ទាល់នោះទេ។ យោងតាមរបាយការណ៍ ADBI ដែលត្រូវបានបង្កើតឡើង នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ មានមនុស្សសរុបចំនួន ៦៥ នាក់ បានចុះឈ្មោះសម្រាប់ការចេញផ្សាយចុងក្រោយ ដែលក្នុងនោះ ១០ នាក់ បានចុះឈ្មោះរួចហើយ ក្នុងអំឡុងពេលអនុវត្តសាកល្បង ប៉ុន្តែមិនបានបញ្ចប់វគ្គសិក្សាមួយចំនួន (ឬវគ្គសិក្សាណាមួយ) នៅដំណាក់កាលធ្វើតេស្ត។

48. ចំនួនលទ្ធផលនៃការបញ្ចប់ត្រូវបានប្រមូលផ្តុំដូចខាងក្រោម៖

| វគ្គសិក្សា | ចំនួនអ្នកចុះឈ្មោះដែលមិនបានបញ្ចប់ក្នុងអំឡុងពេលអនុវត្តសាកល្បង | ចំនួនអ្នកចុះឈ្មោះថ្មី ក្រោយពេលអនុវត្តសាកល្បង | ចំនួនអ្នកបញ្ចប់ដោយជោគជ័យ ក្នុងចំណោមអ្នកចុះឈ្មោះថ្មី ក្រោយពេលអនុវត្តសាកល្បង | ចំនួនអ្នកចុះឈ្មោះសម្រាប់ការអនុវត្តសាកល្បង ប៉ុន្តែបានបញ្ចប់ក្រោយពេលអនុវត្តសាកល្បង | ចំនួនសរុបនៃអ្នកបញ្ចប់ដោយជោគជ័យក្រោយពេលអនុវត្តសាកល្បង |
|---|---|---|---|---|---|
| សេចក្តីផ្តើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ៦២ | ៥៦ | ៥១ | ៦ | ៥៧ |
| សិទ្ធិ និងកាតព្វកិច្ចនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ៦០ | ៥៥ | ៥៤ | ៥ | ៥៩ |
| សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត | ៦៥ | ៥៧ | ៥៦ | ៨ | ៦៤ |

49. ដូច្នេះ អត្រាបញ្ចប់ដោយជោគជ័យជាមធ្យមនៅក្នុងវគ្គសិក្សាទាំងបី ក្រោយពេលបិទការធ្វើតេស្តសាកល្បងគឺ ៩៦%។ Spreadsheet ដែលបង្ហាញអំពីការបញ្ចប់ ត្រូវបានភ្ជាប់មកជាមួយ ជាឧបសម្ព័ន្ធទី៨។

50. ព្រឹត្តិការណ៍សំខាន់ទី៤ ត្រូវបានរាយការណ៍ថា បានបញ្ចប់នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣។

# ព្រឹត្តិការណ៍សំខាន់ទី៥

51. ព្រឹត្តិការណ៍សំខាន់ទី៥ រួមមានរបាយការណ៍សង្ខេបបច្ចុប្បន្ន រួមទាំងដំណើរការនៃមតិត្រឡប់ ដែលទទួលបានពីការចេញផ្សាយវគ្គសិក្សាលើកចុងក្រោយ។ ក្នុងដំណាក់កាលនេះ វគ្គសិក្សាក៏ត្រូវបាន

ចេញផ្សាយជាសាធារណៈ ដោយ ADBI តាមរយៈការលុបចោលការការពារដោយពាក្យសម្ងាត់ ព្រមទាំងទម្រង់មតិត្រឡប់ផងដែរ។ ប្រតិចារិកជាភាសាខ្មែរក៏ត្រូវបានលុបចោលផងដែរ ពីព្រោះវគ្គសិក្សាត្រូវបានបើកចំហរសម្រាប់អ្នកប្រើប្រាស់កាន់តែទូលំទូលាយ នៅទូទាំងអាស៊ី[12] មិនត្រឹមតែអ្នកប្រើប្រាស់ដែលជាជនជាតិកម្ពុជាប៉ុណ្ណោះទេ។ ADBI ក៏នឹងធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីវគ្គសិក្សាទាំងនេះ នៅពេលដែលវគ្គសិក្សាទាំងនេះអាចចូលប្រើប្រាស់បានដោយអ្នកសិក្សាទូទៅ។

52. មតិត្រឡប់ត្រូវបានប្រមូលពីអ្នកចូលរួមចំនួន ៥៩ នាក់ក្នុងដំណាក់កាលនេះ ដោយមានការចាត់ថ្នាក់សរុបចំនួន ១៦៩ ត្រូវបានផ្តល់ជូន នៅក្នុងវគ្គសិក្សាទាំងបី។ ការចាត់ថ្នាក់សម្រាប់វគ្គសិក្សាទាំងបីត្រូវបានភ្ជាប់មកជាមួយ ជាឧបសម្ព័ន្ធទី៩ មាត្រដ្ឋាននៃការចាត់ថ្នាក់ (៥ គឺខ្ពស់បំផុត និង ១ គឺទាបបំផុត) នៅក្នុងវគ្គសិក្សាទាំងបីគឺ៖

| ការចាត់ថ្នាក់ | ទិដ្ឋភាពដែលបានចាត់ថ្នាក់ | មាតិកានៃវគ្គសិក្សា | បទពិសោធន៍នៃការសិក្សា | ការវាយតម្លៃ |
|---|---|---|---|---|
| ៥ | | ៥៣% | ៤០% | ៤៤% |
| ៤ | | ៣៩% | ៤៦% | ៤៣% |
| ៣ | | ៧% | ១៣% | ១១% |
| ២ | | ១% | ១% | ២% |
| ១ | | 0% | 0% | 0% |

53. ចំពោះវគ្គសិក្សានីមួយ ការចាត់ថ្នាក់មានដូចខាងក្រោម៖

- សេចក្តីផ្តើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖ ប្រមូលបានការចាត់ថ្នាក់ចំនួន ៥៨

| ការចាត់ថ្នាក់ | ទិដ្ឋភាពដែលបានចាត់ថ្នាក់ | មាតិកានៃវគ្គសិក្សា | បទពិសោធន៍នៃការសិក្សា | ការវាយតម្លៃ |
|---|---|---|---|---|
| ៥ | | ៤៥% | ៣៣% | ៤៣% |
| ៤ | | ៤៣% | ៤០% | ៤០% |
| ៣ | | ១២% | ២៧% | ១៧% |
| ២ | | 0% | 0% | 0% |
| ១ | | 0% | 0% | 0% |

- សិទ្ធិ និងកាតព្វកិច្ចនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖ ប្រមូលបានការចាត់ថ្នាក់ចំនួន ៤៧

[12] គិតត្រឹមខែកញ្ញា ឆ្នាំ ២០២៣ អ្នកប្រើប្រាស់នៅអាស៊ី និងកន្លែងដទៃទៀត ជិត ៩៦.០០០ នាក់ បានជាវថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ ADBI។

| ការចាត់ថ្នាក់ | ទិដ្ឋភាពដែលបានចាត់ថ្នាក់ | មាតិកានៃវគ្គសិក្សា | បទពិសោធន៍នៃការសិក្សា | ការវាយតម្លៃ |
|---|---|---|---|---|
| ៥ | | ៥៨% | ៤៥% | ៣៨% |
| ៤ | | ៣៤% | ៤៥% | ៤៧% |
| ៣ | | ៧% | ៩% | ១១% |
| ២ | | ១% | ១% | ៤% |
| ១ | | 0% | 0% | 0% |

- សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត៖ ប្រមូលបានការចាត់ថ្នាក់ចំនួន ៦៤

| ការចាត់ថ្នាក់ | ទិដ្ឋភាពដែលបានចាត់ថ្នាក់ | មាតិកានៃវគ្គសិក្សា | បទពិសោធន៍នៃការសិក្សា | ការវាយតម្លៃ |
|---|---|---|---|---|
| ៥ | | ៥៦% | ៤២% | ៥0% |
| ៤ | | ៣៩% | ៥៣% | ៤២% |
| ៣ | | ៣% | ៣% | ៥% |
| ២ | | ២% | ២% | ៣% |
| ១ | | 0% | 0% | 0% |

54. មតិត្រឡប់ជាលក្ខណៈបើកចំហរសរុបចំនួន ៩0 ត្រូវបានប្រមូលពីអ្នកចូលរួមចំនួន ៥៩ នាក់ មិនរួមបញ្ចូល មតិត្រឡប់ ដែលចែងថា "គ្មានយោបល់" ឬមតិយោបល់ដូចគ្នា នៅក្នុងទម្រង់មតិត្រឡប់ខុសគ្នា។ មតិយោបល់ទាំងនេះបានចង្អុលបង្ហាញអំពីសេចក្តីពេញចិត្តនៅកម្រិតខ្ពស់ និងការថ្លែងអំណរគុណជាទូទៅ រួមជាមួយមតិវិជ្ជមានចំនួន ៧៦ ដែលមានប្រវែងខុសៗគ្នា និងការថ្លែងអំណរគុណ អ្នកចូលរួមចំនួនបួននាក់បានបង្ហាញអំពីក្តីសង្ឃឹម និងចំណាប់អារម្មណ៍ក្នុងការមើលឃើញការបណ្តុះបណ្តាលប្រភេទនេះបន្ថែមទៀត នាពេលអនាគត និងមតិយោបល់មួយចំនួនតូច ដែលភាគច្រើនជាការរិះគន់ក្នុងន័យស្ថាបនា ដែលនឹងលើកឡើងនៅខាងក្រោម។ មតិយោបល់បើកចំហ ជាលក្ខណៈអនាមិក ដែលត្រូវបានប្រមូលផ្តុំពីវគ្គសិក្សាទាំងបី ត្រូវបានភ្ជាប់មកជាមួយ នៅក្នុងឧបសម្ព័ន្ធទី១0។

55. ចំពោះមាតិកា ការសង្កេតការណ៍ដូចខាងក្រោម ត្រូវបានធ្វើឡើង (ជាពាក្យពេចន៍ជាក់ស្តែង ដែលត្រូវបានថតចម្លងពីទម្រង់មតិត្រឡប់)៖

ជាទូទៅ វគ្គសិក្សាគួរតែពន្យល់បន្ថែម ទាក់ទងនឹងដំណើរការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងវិធីអូព្រឹត្តិការណ៍អនឡាញ។

ការប្រើឧទាហរណ៍បន្ថែម អាចជួយដល់ការពន្យល់កាន់តែច្បាស់ និងអាចចងចាំបាន។

ពិបាកយល់ ប៉ុន្តែការសង្ខេបអាចជួយបាន។

ការពន្យល់កាន់តែលម្អិត និងបានល្អអំពីប្រធានបទនេះ។

វគ្គសិក្សាទីពីរនេះគឺ ពិបាកបន្តិចសម្រាប់ខ្ញុំ ពីព្រោះវាទាក់ទងនឹងច្បាប់មួយចំនួន ប៉ុន្តែវាពិតជាសំខាន់ខ្លាំងណាស់។

មានចំណុចមួយចំនួន ដែលខ្ញុំយល់មិនច្បាស់។

56. មតិទាំងប្រាំមួយនេះហាក់បីដូចជាចង្អុលបង្ហាញអំពីការលំបាកទៅតាមកម្រិតនៃមាតិកា និងតម្រូវការការពន្យល់បន្ថែម។ នៅខណៈពេលដែលមាតិកាមួយចំនួនអាចមានការលំបាកសម្រាប់អ្នកប្រើប្រាស់ទូទៅនោះ អ្នកចូលរួមភាគច្រើនបានរកឃើញថា វាសមរម្យ និងអាចគ្រប់គ្រងបាន។ ដោយសារការបង្រៀនជាវីដេអូដែលបានថតទុក ត្រូវស្ថិតក្នុងពេលវេលាកំណត់ ដែលកំណត់ដោយ ADBI សម្រាប់រាល់វគ្គសិក្សាតាមអេឡិចត្រូនិករបស់ពួកគេនោះ បទបង្ហាញត្រូវបានបង្រួម និងមានការអនុវត្តជាក់ស្តែងតិចជាងការគ្រោងទុកកាលពីដំបូង។ លំហាត់អនុវត្តជាក់ស្តែងដែលបានគ្រោងទុកកាលពីដំបូងក៏ត្រូវបានបោះបង់ចោលផងដែរ ដោយសារដែនកំណត់ដែល កំណត់ដោយថ្នាលដំណើរការ។

57. ទាក់ទងនឹងការដំណើរការវគ្គសិក្សា មតិរិះគន់ខាងក្រោមត្រូវបានកត់ត្រាទុក៖

នឹងមានការកោតសរសើរយ៉ាងខ្លាំង ប្រសិនបើយើងអាចចូលទៅទាញយកបទបង្ហាញជាស្លាយជាមុន។

គ្រូបង្រៀន បង្រៀនលឿនបន្តិច។

គួរតែមានថ្នាក់រៀនអនឡាញជាលក្ខណៈបន្តផ្ទាល់ ដូច្នេះអ្នកចូលរួមអាចសួរសំណួរបានកាន់តែច្រើន។

ខ្ញុំស្នើឱ្យមានវគ្គបន្តផ្ទាល់សម្រាប់មេរៀននីមួយៗ ដើម្បីឱ្យអ្នកចូលរួមអាចចូលរួមបានកាន់តែច្រើន។

58. ទោះបីជាអ្នកប្រឹក្សាយោបល់បានស្នើឱ្យអនុញ្ញាតឱ្យមានការចូលប្រើប្រាស់ស្លាយ power point ដែលប្រើនៅក្នុងការបង្រៀនជាវីដេអូក៏ដោយ ក៏សំណើនេះត្រូវបានបដិសេធដោយ ADBI ដែលជាអ្នកដំណើរការ។ ផ្ទុយទៅវិញ ប្រតិចារិកនៃការបង្រៀនទាំងស្រុង ត្រូវបានផ្តល់ជូនសិស្ស ដែលគួរតែមានអត្ថប្រយោជន៍ស្មើគ្នា ប្រសិនបើមិនមានអត្ថប្រយោជន៍ច្រើនជាងនោះទេ។ ល្បឿននៃការបង្រៀនជាវីដេអូអាចត្រូវបានកែសម្រួលនៅពេលមើល ហើយវីដេអូអាចត្រូវបានផ្អាក និងចាក់ឡើងវិញជាច្រើនដង តាមការចាំបាច់។ ដោយគិតដល់មុខងារទាំងនេះ ល្បឿនដើមនៃការធ្វើបទបង្ហាញមិនគួរប៉ះពាល់ដល់សមត្ថភាពរបស់អ្នកសិក្សាក្នុងការអនុវត្តតាមនោះទេ។

59. បន្ថែមពីលើមតិយោបល់ចំនួនពីរនៅដំណាក់កាលនេះ សំណើសុំថ្នាក់រៀនបន្តផ្ទាល់ក៏ត្រូវបានធ្វើឡើងក្នុងអំឡុងពេលធ្វើតេស្តសាកល្បងផងដែរ។ ដូចបានចង្អុលបង្ហាញនៅក្នុងរបាយការណ៍ក្រោយពេលធ្វើតេស្ត នៅខណៈពេលដែលការបណ្តុះបណ្តាលបន្តផ្ទាល់អាចនាំមកនូវអត្ថប្រយោជន៍បន្ថែមមួយចំនួននោះ វគ្គសិក្សាត្រូវបានរៀបចំឡើងដើម្បីឲ្យសិស្សដំណើរការដោយខ្លួនឯង និងតាម

អនឡាញ ដើម្បីបន្តអាចចូលប្រើប្រាស់បាន និងមាននិរន្តរភាពសម្រាប់អ្នកចូលរួមនាពេលអនាគត ដែលមានសាវតាខុសៗគ្នា។ វិធីសាស្ត្រចែកចាយនេះត្រូវបានអនុម័តដោយអ្នកទទួលផល។ វគ្គបន្តផ្ទាល់សម្រាប់មេរៀននីមួយៗនាពេលបច្ចុប្បន្នគឺ លើសពីសមត្ថភាព និងធនធានដែលមានសម្រាប់ TA នេះ ប៉ុន្តែអាចត្រូវបានពិចារណាសម្រាប់កម្មវិធីនាពេលអនាគត។

60. ជាចុងក្រោយ មានមតិយោបល់ចំនួនបី ទាក់ទងនឹងការវាយតម្លៃ៖

គួរតែមានសំណួរធ្វើតេស្ត និងលំហាត់បន្ថែម

សំណួរធ្វើតេស្តមានការភ័ន្តច្រឡំបន្តិច

ទោះបីជាសិស្សអាចបញ្ចប់វគ្គសិក្សាដោយជោគជ័យក៏ដោយ ប៉ុន្តែសិស្សអាចធ្វើតេស្តម្តងទៀតបាន និងអាចចម្លងចម្លើយត្រឹមត្រូវ ដែលបានផ្តល់ជូន ដោយសិស្សមិនបានរៀនសូត្របានច្រើននោះទេ។

61. ទំហំ និងប្រភេទសំណួរធ្វើតេស្តត្រូវបានរឹតត្បិតដោយគោលការណ៍ណែនាំដែលផ្តល់ជូនដោយថ្នាលដំណើរការ ADBI។ លំហាត់ជាក់ស្តែងដែលត្រូវបានរៀបចំកាលពីដំបូង ត្រូវតែបោះបង់ចោលដោយសារហេតុផលដូចគ្នានេះដែរ។ យើងមិនច្បាស់ថាតើអ្នកបញ្ចេញមតិយល់ថាសំណួរធ្វើតេស្តបង្កការភ័ន្តច្រលំដោយរបៀបណានោះទេ ដូច្នេះអ្នកប្រឹក្សាយោបល់ពុំមានអនុសាសន៍លើការកែលម្អនោះទេ។ មតិចុងក្រោយគឺដូចគ្នាទៅនឹងមតិដែលបានផ្តល់ជូនក្នុងអំឡុងពេលធ្វើតេស្តដែលបានចង្អុលបង្ហាញថា សិស្សចម្លងចម្លើយត្រឹមត្រូវដែលពួកគេអាចមើលឃើញ។ ការកំណត់ដែលកាលពីមុនបានអនុញ្ញាតឲ្យមានការចម្លងចម្លើយបែបនេះ ត្រូវបានផ្លាស់ប្តូរ ហើយពួកគេមិនអាចមើលឃើញចម្លើយត្រឹមត្រូវនោះទេ រហូតដល់ពួកគេបញ្ចប់សំណួរធ្វើតេស្ត ដែលមានចម្លើយត្រឹមត្រូវយ៉ាងតិច ៨០%។ នៅខណៈពេលដែលចំនួនសំណួរអាចធ្វើឱ្យមានភាពងាយស្រួលក្នុងការកែលម្អនៅពេលធ្វើតេស្តលើកទីពីរនោះ សំណួរពហុជ្រើសរើស និងទំហំសំណួរធ្វើតេស្ត ដែលមានកម្រិត មានដែនកំណត់របស់វា។ លើសពីនេះទៀត សំណួរធ្វើតេស្តមិនមែនជាប្រភពចម្បងនៃការរៀនសូត្រនោះទេ ការបង្រៀនជាវីដេអូដែលបានថតទុក និងធនធានអានដែលផ្តល់ជូន គឺជាប្រភពចម្បងនៃការរៀនសូត្រ។

62. អាស្រ័យហេតុនេះ អ្នកប្រឹក្សាយោបល់ចាត់ទុកថា ការចេញផ្សាយលើកចុងក្រោយទទួលបានជោគជ័យ ដោយចំនួនអ្នកចូលរួមដែលត្រូវបានតម្រូវ ជាង ៥០ នាក់ បានបញ្ចប់វគ្គសិក្សានីមួយៗដោយជោគជ័យ ហើយការចាត់ថ្នាក់ និងមតិត្រឡប់ដែលបានផ្តល់ជូន បានចង្អុលបង្ហាញថា សេចក្តីពេញចិត្តជារួម មានកម្រិតខ្ពស់។ ដោយផ្អែកលើចំណុចនេះ ADBI នឹងចេញផ្សាយវគ្គសិក្សាសម្រាប់ការចូលប្រើប្រាស់ជាសាធារណៈដោយបើកចំហ នៅលើថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ពួកគេ។

# សេចក្តីសន្និដ្ឋាន

63. ជាតុចេញទី២ សម្រាប់ TA-៦៦១៨ REG (CAM) ត្រូវបានបញ្ចប់ដោយជោគជ័យ តាមរយៈការបង្កើតវគ្គលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកចំនួនបី ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលស័ក្តិសមសម្រាប់ទាំងអ្នកប្រើប្រាស់ទូទៅ និងអ្នកសិក្សាដែលមកពីផ្នែកអាជីវកម្ម និងរដ្ឋាភិបាល។ វគ្គសិក្សាទាំងនេះមាននៅលើថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ ADBI នៅ https://elearning-adbi.org/។

64. ដើម្បីចូលប្រើប្រាស់វគ្គសិក្សានេះ ជាដំបូង សិស្សត្រូវចុះឈ្មោះនៅក្នុងថ្នាល ដើម្បីបង្កើតប្រវត្តិរូប និងព័ត៌មានលម្អិតនៃការឡុកអ៊ីន។ រាល់វិញ្ញាបនបត្របញ្ចប់ការសិក្សានឹងត្រូវបានចេញតាមឈ្មោះដែលបានបង្ហាញនៅក្នុងការចុះឈ្មោះនេះ។

65. បន្ទាប់ពីបានបង្កើតប្រវត្តិរូបរួចរាល់ហើយ សិស្សអាចចូលប្រើប្រាស់វគ្គសិក្សាទាំងបីបាន តាមតំណភ្ជាប់ ដែលបានបង្ហាញនៅខាងក្រោម។

    វគ្គសិក្សាទី១៖ សេចក្តីផ្តើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

    https://elearning-adbi.org/courses/introduction-to-e-commerce/

    វគ្គសិក្សាទី២៖ សិទ្ធិ និងកាតព្វកិច្ចនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
    https://elearning-adbi.org/courses/rights-and-obligations-in-e-commerce/

    វគ្គសិក្សាទី៣៖ សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត
    https://elearning-adbi.org/courses/cybersecurity/

66. វគ្គសិក្សាទាំងនេះត្រូវបានធ្វើតេស្តដោយក្រុមអ្នកចូលរួមដែលបានចុះឈ្មោះចំនួន ៥៦ នាក់ ដែលក្នុងចំណោមពួកគេ ៤៧ នាក់បានបញ្ចប់ការវាយតម្លៃដោយជោគជ័យ និងទទួលបានវិញ្ញាបនបត្រពីវគ្គសិក្សាទាំងបី នៅខណៈពេលដែល ៥០ នាក់ បានបញ្ចប់ត្រឹមតែវគ្គសិក្សាមួយចំនួនក្នុងចំណោមវគ្គសិក្សាទាំងបីប៉ុណ្ណោះ។ អត្រាបញ្ចប់ដោយជោគជ័យនៃវគ្គសិក្សាទាំងបីនៅក្នុងការអនុវត្តសាកល្បងគឺ ប្រហែល ៨៤%។

67. ក្នុងអំឡុងពេលនៃការចេញផ្សាយលើកចុងក្រោយ បន្ទាប់ពីបានទទួលមតិត្រឡប់ និងបានធ្វើការកែលម្អមួយចំនួន វគ្គសិក្សាទាំងនេះត្រូវបានចូលរួមដោយក្រុមអ្នកចូលរួមថ្មីៗចំនួន ៥៥ នាក់ និងដប់នាក់ ដែលបានចុះឈ្មោះនៅក្នុងការអនុវត្តសាកល្បង។ ក្នុងចំណោមពួកគេ អ្នកចូលរួមសរុបចំនួន ៥៨ នាក់ បានទទួលវិញ្ញាបនបត្របញ្ចប់ការសិក្សាដោយជោគជ័យពីវគ្គសិក្សាទាំងបី និងប្រាំមួយនាក់បានទទួលវិញ្ញាបនបត្រសម្រាប់តែវគ្គសិក្សាមួយ ឬពីរប៉ុណ្ណោះ ក្នុងចំណោមវគ្គសិក្សាទាំងបី។ អត្រាបញ្ចប់ដោយជោគជ័យនៃវគ្គសិក្សាទាំងបីនៅក្នុងការចេញផ្សាយលើកចុងក្រោយគឺ ៥៨%។

68. នៅក្នុងដំណាក់កាលទាំងពីរ មានអ្នកចូលរួមសរុប ១១១ នាក់ ដែលបានចុះឈ្មោះចូលរួមវគ្គសិក្សាស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ក្នុងចំណោមពួកគេ ៩៧ នាក់បានបញ្ចប់វគ្គសិក្សាទាំងបី ដោយបានទទួលវិញ្ញាបនបត្របញ្ចប់ការសិក្សាដោយជោគជ័យ បន្ទាប់ពីបានប្រឡងជាប់សំណួរវាយតម្លៃទាំងបី។ ក្នុងចំណោមអ្នកចុះឈ្មោះចំនួន ១៤ នាក់ ដែលនៅសល់ ប្រាំនាក់បានបញ្ចប់វគ្គសិក្សាចំនួនពីរ បីនាក់បានបញ្ចប់វគ្គសិក្សាតែមួយប៉ុណ្ណោះ និងម្នាក់ទៀតមិនបានបញ្ចប់វគ្គសិក្សាណាមួយក្នុងចំណោមវគ្គសិក្សាទាំងបីនោះទេ។ បញ្ជីចុះឈ្មោះ និងបញ្ជីបញ្ចប់ការសិក្សា នៅក្នុងការអនុវត្តសាកល្បង និងការចេញផ្សាយលើកចុងក្រោយ រួមគ្នា ត្រូវបានភ្ជាប់មកជាមួយ ជាឧបសម្ព័ន្ធទី១១។

69. ជាលទ្ធផល របាយការណ៍បច្ចុប្បន្នអាចបញ្ជាក់អំពីការអនុលោមតាមលក្ខខណ្ឌតម្រូវនៃ DMF ដែលមានអ្នកចូលរួមយ៉ាងតិច ៥០ នាក់ បានបញ្ចប់ការសិក្សា និងអ្នកចូលរួមយ៉ាងតិច ៥០% បានប្រឡងជាប់ការវាយតម្លៃវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។

# ឧបសម្ព័ន្ធទី ១

សំណួរសម្រាប់ក្រសួងពាណិជ្ជកម្ម ដែលចាំបាច់ដើម្បីបង្កើតក្របខណ្ឌ វិធីសាស្ត្រ និងមាតិកានៃការអភិវឌ្ឍវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (ធាតុចេញទី២) ដែលត្រូវបានតម្រូវ ស្របតាម TA រួមជាមួយចម្លើយដែលផ្តល់ជូនដោយ TTRI នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០២២។

| សំណួរពីអ្នកប្រឹក្សាយោបល់ | | ចម្លើយ |
|---|---|---|
| ១ | តើ MOC នឹងជួយប្រមូលទិន្នន័យតាមរយៈកម្រង សំណួរអនឡាញ ពីមន្ត្រីរដ្ឋាភិបាល ដើម្បីវាយតម្លៃកម្រិតចំណេះដឹងពាក់ព័ន្ធដែលមានស្រាប់ដែរឬទេ? | បាទ/ចាស MoC អាចជួយតាមកម្រិតដែលបានព្រមព្រៀងគ្នារវាងភាគីទាំងពីរ។ |
| ២ | តើអ្នកប្រឹក្សាយោបល់អាចចូលប្រើប្រាស់ថ្នាលចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានលើកឡើងនៅក្នុង MOU សម្រាប់ធាតុចេញទី២ ដែរឬទេ? | បាទ/ចាស លើកលែងតែពួកគេមិនបានជូនដំណឹងទៅកាន់នាយកដ្ឋានទទួលបន្ទុក អំពីវត្ថុបំណងនៃការទទួលបានទិន្នន័យទាំងនេះ។ ទិន្នន័យមួយចំនួន នៅពេលបង្ហាញ អាចបង្កផលប៉ះពាល់ដល់ការរក្សាការសម្ងាត់របស់ក្រុមហ៊ុនដែលបានចុះបញ្ជី។ ប៉ុន្តែ TTRI នឹងផ្តល់ជំនួយសម្រាប់នីតិវិធីស្នើសុំ ប្រសិនបើចាំបាច់។ |
| ៣ | តើមានថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដទៃទៀត ដែល MOC រំពឹងទុកនឹងរួមបញ្ចូលនៅក្នុងវគ្គសិក្សានេះដែរឬទេ ហើយប្រសិនបើមាន តើជាថ្នាលណាមួយ? | នេះអាស្រ័យលើភាពជាក់ស្តែង បន្ទាប់ពីមានការពិភាក្សាបន្ថែមទៀត។ CambodiaTrade អាចត្រូវបានរួមបញ្ចូលនៅក្នុងវគ្គសិក្សានេះ ប្រសិនបើ ADB គិតថាល្អ។ |
| ៤ | តើអ្នកប្រើប្រាស់គោលដៅអាចត្រូវបានបង្រៀនជាភាសាអង់គ្លេស ឬតម្រូវឲ្យមានការបកប្រែសម្រាប់វគ្គសិក្សាទាំងមូល? | វាអាស្រ័យលើមាតិកានៃវគ្គសិក្សា ប្រសិនបើមានមាតិកាណាមួយសម្រាប់ SMEs ក្នុងស្រុក ឬមន្ត្រីថ្នាក់ក្រោមជាតិនោះ ការបកប្រែអាចចាំបាច់។ |
| ៥ | ចំពោះអ្នកប្រើប្រាស់គោលដៅ តើ "មន្ត្រីរដ្ឋាភិបាល" មានតួនាទីអ្វីខ្លះ នៅក្នុង MOU ដែលបានយោងដល់? | តួនាទីរបស់មន្ត្រីរដ្ឋាភិបាល ដូចមានចែងនៅក្នុង MoU នេះគឺ ផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដល់វិស័យឯកជន និងផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីថ្នាក់ក្រោមជាតិ និងវិស័យឯកជន លើផ្នែកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ SMEs ដែលមានសក្តានុពល អាចត្រូវបានកំណត់គោលដៅថាជាអ្នកប្រើប្រាស់ផងដែរ។ |

| | | |
|---|---|---|
| ៦ | តើ "ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ" និងអ្នកប្រឹក្សាយោបល់ ដែល "ផ្សព្វផ្សាយអំពីសម្ភារបណ្តុះបណ្តាលជាសាធារណៈ" នៅក្នុង MOU មានន័យថា វគ្គសិក្សានេះក៏គួរតែកំណត់គោលដៅលើប្រជាជនទូទៅដែរ មែនដែរឬទេ? ប្រសិនបើមែន តើគោលដៅនេះអាចសម្របសម្រួលជាមួយការរំពឹងទុកថា មាតិកាគួរតែតម្រង់ទិសលើអាជីវកម្ម និងច្បាប់ បានដោយរបៀបណា? | វគ្គសិក្សានេះក៏កំណត់គោលដៅចំពោះវិស័យឯកជនដែលពាក់ព័ន្ធនឹងការអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ ជាពិសេសអ្នកដែលកំពុងចាប់ផ្តើមអាជីវកម្មនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ពួកគេនៅប្រទេសកម្ពុជា។ ការកំណត់គោលដៅលើ វិស័យឯកជនដែលពាក់ព័ន្ធនេះ ត្រូវបានសម្របសម្រួលជាមួយអាជីវកម្ម និងច្បាប់រួចហើយ ពីព្រោះអ្នកប្រើប្រាស់ទាំងនេះមានតម្រូវការខ្ពស់ក្នុងការទទួលបានព័ត៌មានឱ្យបានច្បាស់អំពីគំរូអាជីវកម្ម និងច្បាប់ពាក់ព័ន្ធ។ |
| ៧ | តើ MOC (ឬក្រសួងដទៃទៀត) នឹងធានាចំនួនអប្បបរមានៃមន្ត្រីរដ្ឋាភិបាល ដែលចូលរៀនក្នុងវគ្គសិក្សានេះ ដើម្បីសម្រេចគោលដៅនៃ "ការមានអ្នកចូលរួមយ៉ាងតិច ៥0 នាក់" ត្រូវបានកំណត់អត្តសញ្ញាណនៅក្នុង DMF ដែរឬទេ? | បាទ/ចាស ក្រសួងនឹងធានា។ |
| ៨ | តើមានការសិក្សាចំនួនប៉ុន្មានមេរៀន/ម៉ោង ដែលត្រូវបានគ្រប់ដណ្តប់នៅក្នុងវគ្គសិក្សានេះ? | វាអាស្រ័យលើមាតិកាជាក់ស្តែងនៃវគ្គសិក្សា ដោយមានការពិភាក្សាបន្ថែមទៀត។ |
| ៩ | តើជាតុចេញនៃការសិក្សាគន្លឹះអ្វីខ្លះដែលរំពឹងទុកថានឹងទទួលបានពីវគ្គសិក្សានេះ? | អ្នកចូលរួមអាចយល់យ៉ាងច្បាស់អំពីគំរូអាជីវកម្មនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>អ្នកចូលរួមអាចទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីរបៀបដែលច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធដទៃទៀត រួមទាំងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ និង<br>មន្ត្រីរដ្ឋាភិបាល ដែលទទួលបន្ទុកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងថ្នាលឌីជីថល រួមទាំងការចុះបញ្ជីអាជីវកម្មអនឡាញ ឬគម្រោង Go4ecam អាចទាញយកមេរៀនពីការអនុវត្តល្អបំផុត ដើម្បីយកទៅអនុវត្តនៅ MoC។ |
| ១០ | តើមានបញ្ជីមាតិកា/ប្រធានបទ/ទិសដៅជាក់លាក់ដែលបានរំពឹងទុក (ឧ. ការប្រើប្រាស់ជាទូទៅ ការតម្រង់ទិសអាជីវកម្មជាក់ស្តែង ឬការផ្តោតលើច្បាប់) នឹងត្រូវបានរួមបញ្ចូលដែរឬទេ? | បាទ/ចាស មាន។ ចំណុចនេះនឹងត្រូវពិភាក្សាបន្ថែម។ |

| | | |
|---|---|---|
| ១១ | តើមានធនធានការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានស្រាប់ ដែលគួរតែយកមកពិចារណា ដើម្បីជៀសវាងការប្រើប្រាស់ធនធាន/ការបណ្តុះ-បណ្តាលជាន់គ្នាដែរឬទេ? | TTRI កំពុងពិចារណាលើថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកមួយ ប៉ុន្តែការដំណើរការគម្រោងនេះដោយ ADB នឹងបន្ថែមអត្ថប្រយោជន៍ដែលមិនអាចកាត់ថ្លៃបាន និងជាគំរូមួយ មិនមែនជាការអនុវត្តជាន់គ្នានោះទេ។ |
| ១២ | តើមានវិធីសាស្ត្រដែលចង់ប្រើ ដែលវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកគួរតែយកមកប្រើដែរឬទេ? (ឧ. ការសិក្សាដោយឯករាជ្យតាមល្បឿនរបស់សិស្ស ការសិក្សាដោយឯករាជ្យដែលមានកំណត់ពេលវេលា ផ្តល់ការសិក្សាតាមបែបសន្និសីទដោយមានការចូលរួមបន្តផ្ទាល់)។ | យើងចង់អនុវត្តការសិក្សាដោយឯករាជ្យតាមល្បឿនរបស់សិស្ស និងផ្តល់ការសិក្សាតាមបែបសន្និសីទដោយមានការចូលរួមបន្តផ្ទាល់។ |
| ១៣ | ប្រសិនបើការបង្រៀនត្រូវបានផ្តល់ជូន តើមានពេលវេលាជាក់លាក់ណាមួយ (ឧ. x ចំនួនម៉ោងលើ n ចំនួនថ្ងៃ) ដែលចង់កំណត់ដែរទេ? | វាអាស្រ័យលើមាតិកានៃវគ្គសិក្សានីមួយៗ។ |
| ១៤ | តើមានទម្រង់ដែលត្រូវបានរំពឹងទុក/ពេញចិត្តសម្រាប់មាតិកានៃវគ្គសិក្សានេះដែរឬទេ? (ឧ. វីដេអូដែលបានថតទុកមុន/ស្លាយ/សម្ភារអាន/ការពិភាក្សាតាមការផ្សាយបន្តផ្ទាល់) | ទម្រង់នោះគឺ ការរួមបញ្ចូលគ្នានៃស្លាយ សម្ភារអាន និងការពិភាក្សាតាមការផ្សាយបន្តផ្ទាល់ ដើម្បីចូលរួមផ្លាស់ប្តូរគំនិត និងអន្តរកម្មតាមពេលវេលាជាក់ស្តែង។ |
| ១៥ | ប្រសិនបើមានការរួមបញ្ចូលការបញ្ជាក់ តើការវាយតម្លៃត្រូវបានរំពឹងថានឹងត្រូវធ្វើការផ្ទៀងផ្ទាត់ (ហើយប្រសិនបើដូច្នេះ តើនឹងត្រូវផ្ទៀងផ្ទាត់ដោយអ្នកណា) ឬនឹងត្រូវរៀបចំឡើងជាលក្ខណៈស្វ័យប្រវត្តិ ការវាយតម្លៃដោយខ្លួនឯង និង/ឬការវាយតម្លៃដោយមិត្តភ័ក្តិ? | វានឹងត្រូវឆ្លងកាត់ការវាយតម្លៃដោយអ្នករៀបចំការបណ្តុះបណ្តាល ឬដោយមានជំនួយមួយចំនួន (ឬជំនួយផ្តាច់មុខ) ពី TTRI តាមរយៈការវាយតម្លៃក្រោយពេលបណ្តុះបណ្តាល ឬការវាយតម្លៃតាមរយៈកម្រងសំណួរ។ |
| ១៦ | តើវិញ្ញាបនបត្រនឹងត្រូវចេញជាទម្រង់ឌីជីថលដែរឬទេ? បើដូច្នេះមែន តើ MOC មានទម្រង់វិញ្ញាបនបត្រស្តង់ដាររួចហើយឬនៅ? | ដោយសារការបណ្តុះបណ្តាលត្រូវបានធ្វើឡើងតាមអនឡាញ វាជារឿងល្អក្នុងការមានវិញ្ញាបនបត្រឌីជីថល។ MoC ឬ ជាពិសេស TTRI មានទម្រង់ឌីជីថលនៃវិញ្ញាបនបត្របែបនេះ។ |
| ១៧ | តើមានចំនួនរំពឹងទុក និងប្រភេទការវាយតម្លៃដែលពេញចិត្តដែរឬទេ? (ឧ. ការប្រឡងក្រោមការត្រួតពិនិត្យតាមអនឡាញ សំណួរធ្វើតេស្តតាម | វាកាន់តែប្រសើរក្នុងការមានសំណួរធ្វើតេស្តតាមអនឡាញ ដែលផ្តល់ជូនអ្នកចូលរួមនៅពេលបញ្ចប់ការបណ្តុះបណ្តាល ហើយការកែសំណួរធ្វើតេស្តនោះត្រូវបានធ្វើឡើងដោយស្វ័យប្រវត្តិ។ |

| | | |
|---|---|---|
| | អនឡាញ ចម្លើយជាលាយលក្ខណ៍អក្សរ កិច្ចការអនុវត្តជាក់ស្តែង) | |
| ១៨ | តើវគ្គសិក្សានេះនឹងដំណើរការនៅលើថ្នាលអ្វី? | វាមានលក្ខណៈសាមញ្ញ និងកាន់តែងាយស្រួល ក្នុងការប្រើប្រាស់ Zoom ឬ Microsoft Team។ |
| ១៩ | តើមានការដាក់កម្រិត ដែលត្រូវបានកំណត់ដោយថ្នាលនោះដែរឬទេ? (ឧ. ការបកប្រែភាសា និងទំព័រ មាតិកាដែលត្រូវបានហាមឃាត់ កម្រិត/ឧបករណ៍ដែលត្រូវបានហាមឃាត់ ការដាក់កម្រិតលើការចូលប្រើប្រាស់ដោយសមាជិកតែប៉ុណ្ណោះ។ល។) | ពុំមានការដាក់កម្រិតនោះទេ។ |
| ២០ | ប្រសិនបើប្រព័ន្ធសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានតម្រូវ (ឧ. Moodle - ចាំបាច់ ប្រសិនបើគេរំពឹងទុកថានឹងមានការគ្រប់គ្រងសិស្ស និងការវាយតម្លៃ) តើប្រព័ន្ធបែបនោះនឹងត្រូវបានផ្តល់ជូន និងដំណើរការដោយ MOC ឬ ADB? | MoC អាចទទួលបន្ទុកលើការដំណើរការបែបនេះ។ |
| ២១ | ប្រសិនបើតម្រូវឱ្យមានការចូលរួមបន្តផ្ទាល់តាមបែបសន្និសីទ តើថ្នាលសន្និសីទ (ឧ. Zoom) នឹងត្រូវបានផ្តល់ជូនដោយ MOC ឬ ADB? | MoC ក៏អាចផ្តល់ជូនបានដែរ។ |
| ២២ | ប្រសិនបើតម្រូវឱ្យមានការប្រឡងក្រោមការត្រួតពិនិត្យតាមអនឡាញ តើសេវាកម្មបែបនេះ (ឧ. proctorU) នឹងត្រូវបានផ្តល់ជូនដោយ MOC ឬ ADB? | MoC អាចផ្តល់ជូនបាន ប៉ុន្តែធាតុចូលក្នុងការបង្កើតមាតិកានៃការប្រឡង នឹងត្រូវធ្វើសេចក្តីព្រាងរួមគ្នាដោយ MoC និង ADB។ |
| ២៣ | តើមានការដាក់កម្រិតផ្នែកបច្ចេកទេស ដែលគួរតែសន្មតថា មានផលប៉ះពាល់ដល់អ្នកប្រើប្រាស់គោលដៅដែរឬទេ? (ឧ. ប្រព័ន្ធបញ្ជូនទិន្នន័យ (broadband) មានកម្រិត ការមិនមានសូហ្វវែរ ឬកម្មវិធីបន្ថែមជាក់លាក់ ការរឹតត្បិតលើការចូលប្រើប្រាស់ដោយមន្ត្រីរដ្ឋាភិបាល។ល។) | ពុំមានការរឹតបន្តឹងបែបនោះទេ ដោយសារការបណ្តុះបណ្តាលតាមអនឡាញដែលត្រូវបានធ្វើឡើងរហូតមកដល់ពេលនេះ បានដំណើរការដោយរលូន និងទទួលបានលទ្ធផលគួរជាទីពេញចិត្ត។ |
| ២៤ | តើទម្រង់មតិត្រឡប់តាមអនឡាញ ត្រូវបានតម្រូវក្រោយពេលបណ្តុះបណ្តាលនីមួយៗដែរឬទេ? | ប្រាកដណាស់ ទម្រង់មតិត្រឡប់តាមអនឡាញគឺចាំបាច់ខ្លាំងណាស់។ |

# ឧបសម្ព័ន្ធទី២

## មគ្គុទ្ទេសន៍ណែនាំសម្រាប់វគ្គសិក្សាទី១

ក. សេចក្ដីផ្ដើម

| | |
|---|---|
| **ចំណងជើងការបង្រៀនអនឡាញ** | សេចក្ដីផ្ដើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| **សេចក្ដីសង្ខេប** | វគ្គសិក្សានេះពន្យល់ថាតើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគឺជាអ្វី តើអ្នកណាខ្លះអាចជាផ្នែកមួយនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងរបៀបដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។<br>វគ្គនេះមាន ២ មេរៀន៖<br>• ទស្សនាទានមូលដ្ឋាន<br>• បច្ចេកវិទ្យាដែលនៅពីក្រោយការធ្វើជំនួញ |
| **វត្ថុបំណងនៃការសិក្សា**<br><br>**(ចំណុចទី ២-៥)** | • យល់ដឹងអំពីទស្សនាទាន និងពាក្យបច្ចេកទេសនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• ទទួលស្គាល់គំរូពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• យល់ដឹងអំពីសមាសធាតុបច្ចេកវិទ្យាមូលដ្ឋាននៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• យល់ដឹងអំពីមូលដ្ឋាននៃធនាគារអនឡាញ។ |
| **របៀបបញ្ចប់វគ្គសិក្សានេះ** | • មើលវីដេអូមេរៀនចំនួន២<br>• ត្រួតពិនិត្យសម្ភារអាន ដែលអាចចូលប្រើប្រាស់បានដោយបើកចំហ<br>• ប្រឡងជាប់សំណួរធ្វើតេស្ដដោយជោគជ័យ ដោយមានពិន្ទុ ៨/១០ ឬខ្ពស់ជាងនេះ<br>• ឆ្លើយសំណួរមតិត្រឡប់<br>• វិញ្ញាបនបត្រ ដែលមានលេខសម្គាល់តែមួយគត់ នឹងត្រូវបានចេញបន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវគ្គសិក្សាយ៉ាងពេញលេញ។ |
| **ព័ត៌មានទំនាក់ទំនង** | Lilian Tan អ្នកប្រឹក្សាយោបល់អំពីការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក<br>វិទ្យាស្ថាននៃធនាគារអភិវឌ្ឍន៍អាស៊ី<br>ltan@adbi.org |
| **សម្ភារអានដែលត្រូវបានណែនាំសម្រាប់គ្រប់មេរៀនទាំងអស់** | • Martin Kutz សេចក្ដីផ្ដើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ការរួមបញ្ចូលគ្នារវាងអាជីវកម្ម និងបច្ចេកវិទ្យាព័ត៌មាន (Bookbook ឆ្នាំ២០១៦)<br>• Efraim Turban et al, សេចក្ដីផ្ដើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងពាណិជ្ជកម្មសង្គម (កំណែលើកទី៤ Springer ឆ្នាំ២០១៧) |

| | |
|---|---|
| | • ឧបករណ៍ស្តង់ដារ ICC-WTO សម្រាប់ជំនួញឆ្លងព្រំដែន ដែលមិនប្រើឯកសារ |

ខ. មេរៀននៃការបង្រៀនតាមអនឡាញ (សូមដាក់កម្រិតលើវគ្គសិក្សាដែលមានរយៈពេលអតិបរមា ចំនួន ១ ម៉ោង)

| | |
|---|---|
| **ចំណងជើងមេរៀនទី១** | ទស្សនាទានមូលដ្ឋាននៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| **បរិយាយត្រួសៗ អំពីមេរៀនទី១** | • តើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគឺជាអ្វី<br>• តើអ្នកណាខ្លះអាចជាផ្នែកមួយនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• តើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកធ្វើអ្វីខ្លះ<br>• ប្រភេទខុសៗគ្នានៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• គំរូនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| **ធនធាន និងការអានដែលត្រូវបានណែនាំសម្រាប់មេរៀនទី១** | • Martin Kutz សេចក្តីផ្តើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក. ការរួមបញ្ចូលគ្នារវាងអាជីវកម្ម និងបច្ចេកវិទ្យាព័ត៌មាន (Bookbook ឆ្នាំ២០១៦)<br>• Efraim Turban et al, សេចក្តីផ្តើមអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងពាណិជ្ជកម្មសង្គម (កំណែលើកទី៤ Springer ឆ្នាំ២០១៧) |
| **ចំណងជើងមេរៀនទី២** | បច្ចេកវិទ្យានៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| **បរិយាយត្រួសៗ អំពីមេរៀនទី២** | • ដំណោះស្រាយនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• ថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក – ឧទាហរណ៍ជាអន្តរជាតិ និងក្នុងស្រុក ពីប្រទេសកម្ពុជា<br>• ការផ្លាស់ប្តូរទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទ្រង់ទ្រាយធំ (EDI)<br>• ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងធនាគារអនឡាញ |
| **ធនធាន និងការអានដែលត្រូវបានណែនាំសម្រាប់មេរៀនទី២** | • ឧបករណ៍ស្តង់ដារ ICC-WTO សម្រាប់ជំនួញឆ្លងព្រំដែន ដែលមិនប្រើឯកសារ |

គ. ការវាយតម្លៃវគ្គសិក្សា៖ សូមផ្តល់**សំណួរពហុជ្រើសរើស**សរុបចំនួន **៨ សំណួរ** សម្រាប់មេរៀនទាំងពីរ។ គួរតែមានជម្រើសចំនួន ៤ ដែលអាចជាចម្លើយសម្រាប់សំណួរនីមួយៗ ប៉ុន្តែគួរតែមានចម្លើយដែលត្រឹមត្រូវតែមួយប៉ុណ្ណោះ។

*សំណួរដែលមានចម្លើយដែលអាចត្រឹមត្រូវ និងចម្លើយត្រឹមត្រូវ ត្រូវបានផ្តល់ជូន ប៉ុន្តែមិនត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍នេះទេ ដោយសារសំណួរទាំងនោះជាផ្នែកមួយនៃការវាយតម្លៃវគ្គសិក្សាតាមអនឡាញ។*

## មគ្គុទ្ទេសន៍ណែនាំសម្រាប់វគ្គសិក្សាទី២

ឃ. សេចក្តីផ្តើម

| | |
|---|---|
| **ចំណងជើងការបង្រៀនអនឡាញ** | សិទ្ធិ និងកាតព្វកិច្ចនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| **សេចក្តីសង្ខេប** | វគ្គនេះផ្តល់ទិដ្ឋភាពទូទៅអំពីច្បាប់ពាក់ព័ន្ធ ដែលធ្វើនិយ័តកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងពន្យល់ថាតើមានសិទ្ធិ និងកាតព្វកិច្ចអ្វីខ្លះ ដែលច្បាប់ទាំងនេះបានបង្កើតឡើងសម្រាប់អាជីវកម្ម និងអ្នកប្រើប្រាស់ ព្រមទាំងភារកិច្ចប្រកបដោយសីលធម៌ និងការអនុវត្តល្អៗ ដែលត្រូវបានណែនាំសម្រាប់អ្នកប្រើប្រាស់ទាំងពីរប្រភេទ។<br>វគ្គនេះមាន ៣ មេរៀន៖<br>• សេចក្តីផ្តើមអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• សិទ្ធិ និងកាតព្វកិច្ចចំពោះអាជីវកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់ |
| **វត្ថុបំណងនៃការសិក្សា**<br><br>**(ចំណុចទី ២-៥)** | • ការយល់ដឹងជាមូលដ្ឋានអំពីច្បាប់ជាតិ និងលិខិតូបករណ៍អន្តរជាតិ ដែលបង្កើតទ្រង់ទ្រាយលិខិតបទដ្ឋានគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាសកល និងនៅតំបន់អាស៊ីប៉ាស៊ីហ្វិក<br>• សិទ្ធិ និងកាតព្វកិច្ច ទាក់ទងនឹងការបង្កើត និងដំណើរការអាជីវកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈឧទាហរណ៍របស់ប្រទេសកម្ពុជា<br>• សុវត្ថិភាពអ្នកប្រើប្រាស់ សិទ្ធិ និងដំណោះស្រាយវិវាទនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ |
| **របៀបបញ្ចប់វគ្គសិក្សានេះ** | • មើលវីដេអូមេរៀនចំនួន៣<br>• ត្រួតពិនិត្យសម្ភារអាន ដែលអាចចូលប្រើប្រាស់បានដោយបើកចំហ<br>• ប្រឡងជាប់សំណួរធ្វើតេស្តដោយជោគជ័យ ដោយមានពិន្ទុ ៨/១០ ឬខ្ពស់ជាងនេះ<br>• ឆ្លើយសំណួរមតិត្រឡប់<br>• វិញ្ញាបនបត្រ ដែលមានលេខសម្គាល់តែមួយគត់ នឹងត្រូវបានចេញបន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវគ្គសិក្សាយ៉ាងពេញលេញ។ |

| | |
|---|---|
| **ព័ត៌មានទំនាក់ទំនង** | Lilian Tan អ្នកប្រឹក្សាយោបល់អំពីការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក<br>វិទ្យាស្ថាននៃធនាគារអភិវឌ្ឍន៍អាស៊ី<br>ltan@adbi.org |
| **សម្ភារអានដែលត្រូវបានណែនាំសម្រាប់គ្រប់មេរៀនទាំងអស់** | • កិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• ក្រមប្រតិបត្តិអាជីវកម្មអនឡាញអាស៊ាន<br>• កិច្ចព្រមព្រៀងលើក្របខណ្ឌ UNESCAP ស្តីពីការសម្របសម្រួលជំនួញឆ្លងព្រំដែន ដែលគ្មានឯកសារ នៅអាស៊ី និងប៉ាស៊ីហ្វិក<br>• គំរូច្បាប់ UNCITRAL ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• គំរូច្បាប់ UNCITRAL ស្តីពីហត្ថលេខាអេឡិចត្រូនិក<br>• គំរូច្បាប់ UNCITRAL ស្តីពីកំណត់ត្រាដែលអាចបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិក<br>• ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃប្រទេសកម្ពុជា<br>• ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នៃប្រទេសកម្ពុជា។ |

ង. មេរៀននៃការបង្រៀនតាមអនឡាញ (សូមដាក់កម្រិតលើវគ្គសិក្សាដែលមានរយៈពេលអតិបរមាចំនួន ១ ម៉ោង)

| | |
|---|---|
| **ចំណងជើងមេរៀនទី១** | សេចក្តីផ្តើមអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| **បរិយាយត្រួសៗអំពីមេរៀនទី១** | • ក្រមខណ្ឌច្បាប់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមទស្សនៈនៃច្បាប់អន្តរជាតិ និងច្បាប់ជាតិ<br>• ទិដ្ឋភាពទូទៅនៃការងារអភិវឌ្ឍន៍ច្បាប់កាន់តែទូលំទូលាយ ដែលពាក់ព័ន្ធសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក<br>• ច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្តិ ដែលធ្វើនិយ័តកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈឧទាហរណ៍របស់ប្រទេសកម្ពុជា។ |
| **ធនធាន និងការអានដែលត្រូវបានណែនាំសម្រាប់មេរៀនទី១** | • កិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• ក្រមប្រតិបត្តិអាជីវកម្មអនឡាញអាស៊ាន<br>• កិច្ចព្រមព្រៀងលើក្របខណ្ឌ UNESCAP ស្តីពីការសម្របសម្រួលជំនួញឆ្លងព្រំដែន ដែលគ្មានឯកសារ នៅអាស៊ី និងប៉ាស៊ីហ្វិក<br>• គំរូច្បាប់ UNCITRAL ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• គំរូច្បាប់ UNCITRAL ស្តីពីហត្ថលេខាអេឡិចត្រូនិក<br>• គំរូច្បាប់ UNCITRAL ស្តីពីកំណត់ត្រាដែលអាចបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិក |
| **ចំណងជើងមេរៀនទី២** | សិទ្ធិ និងកាតព្វកិច្ចចំពោះអាជីវកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |

| | |
|---|---|
| **បរិយាយត្រួសៗ អំពីមេរៀនទី២** | • ការចុះបញ្ជីអាជីវកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈឧទាហរណ៍របស់ប្រទេសកម្ពុជា<br>• ការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិក ការផ្ទេរប្រាក់ កម្មសិទ្ធិបញ្ញា ការការពារអ្នកប្រើប្រាស់ និងទិន្នន័យ និងច្បាប់ពន្ធដារ ដែលមានផលប៉ះពាល់ដល់អាជីវកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• ក្របប្រតិបត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| **ធនធាន និងការអានដែលត្រូវបានណែនាំសម្រាប់មេរៀនទី២** | • ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃប្រទេសកម្ពុជា |
| **ចំណងជើងមេរៀនទី៣** | សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់ |
| **បរិយាយត្រួសៗ អំពីមេរៀនទី៣** | • សុវត្ថិភាព និងឯកជនភាពតាមអនឡាញ និងនៅក្នុងធនាគារអនឡាញ<br>• សិទ្ធិអ្នកប្រើប្រាស់ និងការដោះស្រាយវិវាទ<br>• មតិត្រឡប់ និងការត្រួតពិនិត្យឡើងវិញ។ |
| **ធនធាន និងការអានដែលត្រូវបានណែនាំសម្រាប់មេរៀនទី៣** | • ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នៃប្រទេសកម្ពុជា |

ច. ការវាយតម្លៃវគ្គសិក្សា៖ សូមផ្តល់**សំណួរពហុជ្រើសរើស**សរុបចំនួន **១០ សំណួរ** សម្រាប់មេរៀនទាំងបី។ គួរតែមានជម្រើសចំនួន ៤ ដែលអាចជាចម្លើយសម្រាប់សំណួរនីមួយៗ ប៉ុន្តែគួរតែមានចម្លើយដែលត្រឹមត្រូវតែមួយប៉ុណ្ណោះ។

*សំណួរដែលមានចម្លើយដែលអាចត្រឹមត្រូវ និងចម្លើយត្រឹមត្រូវ ត្រូវបានផ្តល់ជូន ប៉ុន្តែមិនត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍នេះទេ ដោយសារសំណួរទាំងនោះជាផ្នែកមួយនៃការវាយតម្លៃវគ្គសិក្សាតាមអនឡាញ។*

## មគ្គុទ្ទេសន៍ណែនាំសម្រាប់វគ្គសិក្សាទី៣

ឆ. សេចក្តីផ្តើម

| | |
|---|---|
| **ចំណងជើងការបង្រៀនអនឡាញ** | សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត |

| | |
|---|---|
| **សេចក្តីសង្ខេប** | វគ្គសិក្សានេះពន្យល់ថាតើសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិតគឺជាអ្វី ហេតុអ្វីបានជាវាមានសារសំខាន់ និងរបៀបជៀសវាង ទទួលស្គាល់ និងដោះស្រាយហេតុការណ៍តាមប្រព័ន្ធអ៊ីនធឺណិត និងការបំពានលើទិន្នន័យខុសៗគ្នា។<br>វគ្គនេះមាន ៣ មេរៀន៖<br>• ភាពពាក់ព័ន្ធនៃការការពារទិន្នន័យ<br>• ការទទួលស្គាល់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត<br>• ឧបករណ៍រក្សាសុវត្ថិភាពទិន្នន័យ។ |
| **វត្ថុបំណងនៃការសិក្សា**<br><br>(ចំណុចទី ២-៥) | • យល់ដឹងអំពីហានិភ័យនៃការបញ្ជូនទិន្នន័យនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• ទទួលស្គាល់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត និងការបំពានលើទិន្នន័យ<br>• យល់ដឹងអំពីឧបករណ៍រក្សាសុវត្ថិភាពទិន្នន័យមូលដ្ឋាន និងរបៀបប្រើប្រាស់ឧបករណ៍ទាំងនោះ<br>• អាចឆ្លើយតប និងរៀនសូត្រពីហេតុការណ៍តាមប្រព័ន្ធអ៊ីនធឺណិត។ |
| **របៀបបញ្ចប់វគ្គសិក្សានេះ:** | • មើលវីដេអូមេរៀនចំនួន៣<br>• ត្រួតពិនិត្យសម្ភារអាន ដែលអាចចូលប្រើប្រាស់បានដោយបើកចំហ<br>• ប្រឡងជាប់សំណួរធ្វើតេស្តដោយជោគជ័យ ដោយមានពិន្ទុ ៨/១០ ឬខ្ពស់ជាងនេះ<br>• ឆ្លើយសំណួរមតិត្រឡប់<br>• វិញ្ញាបនបត្រ ដែលមានលេខសម្គាល់តែមួយគត់ នឹងត្រូវបានចេញបន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវគ្គសិក្សាយ៉ាងពេញលេញ។ |
| **ព័ត៌មានទំនាក់ទំនង** | Lilian Tan អ្នកប្រឹក្សាយោបល់អំពីការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក<br>វិទ្យាស្ថាននៃធនាគារអភិវឌ្ឍន៍អាស៊ី<br>ltan@adbi.org |
| **សម្ភារអានដែលត្រូវបានណែនាំសម្រាប់គ្រប់មេរៀនទាំងអស់** | • របាយការណ៍ស៊ើបអង្កេតអំពីការបំពានលើទិន្នន័យ (Verizon ឆ្នាំ២០២២)<br>• របាយការណ៍ស្តីពីការគំរាមកំហែងជាសកល (Crowdstrike ឆ្នាំ២០២៣)<br>• ការគំរាមកំហែងដោយឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត Darknet ចំពោះអាស៊ីអាគ្នេយ៍ (UNODC ឆ្នាំ២០២០)<br>• Shannon Williams រដ្ឋសហធនដោះស្រាយការគំរាមកំហែងដោយឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ដែលកំពុងមានការកើនឡើងនៅអាស៊ី (SecurityBrief ឆ្នាំ២០២២) |

ជ. មេរៀននៃការបង្រៀនតាមអនឡាញ (សូមដាក់កម្រិតលើវគ្គសិក្សាដែលមានរយៈពេលអតិបរមាចំនួន ១ ម៉ោង)

| | |
|---|---|
| **ចំណងជើងមេរៀនទី១** | ភាពពាក់ព័ន្ធនៃការការពារទិន្នន័យ |
| **បរិយាយត្រួសៗអំពីមេរៀនទី១** | • ហេតុអ្វីបានជាសុវត្ថិភាពទិន្នន័យគឺជាអ្វីមួយ ដែលបុគ្គល អាជីវកម្ម រដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាលនីមួយៗចាំបាច់ត្រូវយល់ដឹង<br>• ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតនាពេលថ្មីៗនេះ និងគួរឱ្យភ្ញាក់ផ្អើល |
| **ធនធាន និងការអានដែលត្រូវបានណែនាំសម្រាប់មេរៀនទី១** | • Shannon Williams រដ្ឋសហធនដោះស្រាយការគំរាមកំហែងដោយឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ដែលកំពុងមានការកើនឡើងនៅអាស៊ី (SecurityBrief ឆ្នាំ២០២២) |
| **ចំណងជើងមេរៀនទី២** | ទទួលស្គាល់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត |
| **បរិយាយត្រួសៗអំពីមេរៀនទី២** | • ពាក្យបច្ចេកទេស<br>• ប្រភេទខុសៗគ្នានៃការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត និងការបំពានផ្នែកសុវត្ថិភាព<br>• ការណែនាំអំពីរបៀបទទួលស្គាល់ហេតុការណ៍តាមប្រព័ន្ធអ៊ីនធឺណិត |
| **ធនធាន និងការអានដែលត្រូវបានណែនាំសម្រាប់មេរៀនទី២** | • របាយការណ៍ស្តីពីការគំរាមកំហែងជាសកល (Crowdstrike ឆ្នាំ២០២៣)<br>• ការគំរាមកំហែងដោយឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត Darknet ចំពោះអាស៊ីអាគ្នេយ៍ (UNODC ឆ្នាំ២០២០) |
| **ចំណងជើងមេរៀនទី៣** | ឧបករណ៍រក្សាសុវត្ថិភាពទិន្នន័យ |
| **បរិយាយត្រួសៗអំពីមេរៀនទី៣** | • អនុសាសន៍អំពីឧបករណ៍ប្រភេទខុសៗគ្នា ដែលអ្នកប្រើប្រាស់អាចប្រើប្រាស់ដើម្បីជៀសវាងការបំពានលើទិន្នន័យបាន<br>• ការឆ្លើយតបនឹងហេតុការណ៍តាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់អង្គការ។ |
| **ធនធាន និងការអានដែលត្រូវបានណែនាំសម្រាប់មេរៀនទី៣** | • របាយការណ៍ស៊ើបអង្កេតអំពីការបំពានលើទិន្នន័យ (Verizon ឆ្នាំ២០២២) |

ឈ. ការវាយតម្លៃវគ្គសិក្សា៖ សូមផ្តល់**សំណួរពហុជ្រើសរើស**សរុបចំនួន **១០ សំណួរ** សម្រាប់មេរៀនទាំងបី។ គួរតែមានជម្រើសចំនួន ៤ ដែលអាចជាចម្លើយសម្រាប់សំណួរនីមួយៗ ប៉ុន្តែគួរតែមានចម្លើយដែលត្រឹមត្រូវតែមួយប៉ុណ្ណោះ។

*សំណួរដែលមានចម្លើយដែលអាចត្រឹមត្រូវ និងចម្លើយត្រឹមត្រូវ ត្រូវបានផ្តល់ជូន ប៉ុន្តែមិនត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍នេះទេ ដោយសារសំណួរទាំងនោះជាផ្នែកមួយនៃការវាយតម្លៃវគ្គសិក្សាតាមអនឡាញ។*

# ឧបសម្ព័ន្ធទី ៣

## សេចក្ដីផ្ដើមអំពីវែបសាយត៍នៃវគ្គសិក្សាអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក



## About the Course

This course explains what electronic commerce (e-commerce) is, who can be part of it, and how it works.

The course consists of 2 units:

Unit 1: Broad Range of Basic E-Commerce Concepts (41 minutes)

Unit 2: E-commerce Technology (41 minutes)

## Learning Objectives

- Understand e-commerce concepts and terminologies.
- Recognize various e-commerce models.
- Understand basic technology components of e-commerce.
- Understand the basics workings of online banking.

## How to Complete this e-Course

- Watch 2 video lessons
- Review open access reading materials
- Successfully pass quiz with a score of 8/10 or higher
- Answer feedback questions
- Certificate with unique ID will be issued upon completion of course requirements

### Course Content

- Broad Range of Basic E-Commerce Concepts
- E-commerce Technology
- Course Quiz and Feedback Questions
- E-commerce Survey Questions

# វីឌីអូមេរៀនទីមួយ



## ធនធានអានសម្រាប់មេរៀនទីមួយ




## សំណួរវាយតម្លៃ




## សំណួរមតិត្រឡប់



# ទំព័រវគ្គសិក្សាអំពីសិទ្ធិ និងកាតព្វកិច្ចនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក






# ទំព័រវគ្គសិក្សាអំពីសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត






## គំរូវិញ្ញាបនបត្របញ្ចប់ការសិក្សា



ADBInstitute

*Certificate of Completion*

Issued to:

**Dalma Demeter**

for completing the course:

**Introduction to E-commerce**

**18 May 2023 | Course Duration: 1 hour and 22 minutes**

Certificate ID: 84389-168-436-7854

Verify Link: https://elearning-adbi.org/certificate-verifier/?&code=84389-168-436-7854

Tetsushi Sonobe, Dean, ADBI

# ឧបសម្ព័ន្ធទី៤

## ការចុះឈ្មោះ និងការបញ្ចប់វគ្គសិក្សាសាកល្បង

| ល.រ. | ឈ្មោះពេញជាភាសាខ្មែរ | ភេទ | មុខតំណែង | ស្ថាប័ន | វគ្គសិក្សាទី១ | វគ្គសិក្សាទី២ | វគ្គសិក្សាទី៣ |
|---|---|---|---|---|---|---|---|
| 1. | បើ បណ្ឌិត | ប្រុស | អនុប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 2. | ជា គុណឡាក់ | ស្រី | បុគ្គលិក | វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 3. | ជា សម្បត្តិ | ប្រុស | អនុប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តកែប | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 4. | ជ័យ សារឿន | ប្រុស | មន្ត្រី | ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 5. | ឆាយ សុវណ្ណាក់ | ស្រី | ប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 6. | ឈឿង ស្រីពេជ្រ | ស្រី | មន្ត្រី | ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 7. | ឆន ដានី | ស្រី | មន្ត្រី | នាយកដ្ឋាននីតិកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 8. | ឈុំ សូរិយា | ប្រុស | អនុប្រធានការិយាល័យ | នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន/អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 9. | ដុក ផេងភីរាក់ | ប្រុស | មន្ត្រី | នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 10. | ឌុល តុលា | ប្រុស | អនុប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តតាកែវ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 11. | ហៃ វិចិត្រ | ប្រុស | ប្រធានការិយាល័យ | អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 12. | ហេង បូរីណែត | ស្រី | អនុប្រធានការិយាល័យ | នាយកដ្ឋានត្រួតពិនិត្យរដ្ឋបាល និងទទួលពាក្យបណ្តឹង | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 13. | អៀង គន្ធា | ប្រុស | អនុប្រធានមន្ទីរ | មន្ទីរពាណិជ្ជកម្មខេត្តស្ទឹងត្រែង | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 14. | គង់សម្បត្តិ ដាលីស | ស្រី | មន្ត្រី | មន្ទីរពាណិជ្ជកម្មខេត្តកោះកុង | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 15. | គ្រឹម ប៉ែត | ប្រុស | មន្ត្រី | ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 16. | លាន សីណាត | ស្រី | ប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តកំពត | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 17. | លឹម ខេងគង់ | ប្រុស | អនុប្រធាននាយកដ្ឋាន | អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (CCF) | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 18. | លឹម សុគន្ធា | ស្រី | អនុប្រធាននាយកដ្ឋាន | អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (CCF) ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 19. | លី រស្មី | ប្រុស | ប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 20. | នាង ស្រីណែត | ស្រី | មន្ត្រី | នាយកដ្ឋាននាំចេញនាំចូល | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 21. | ងួន ស៊ុនហេង | ប្រុស | មន្ត្រី | នាយកដ្ឋាននាំចេញនាំចូល | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 22. | ញូង វ៉ែន | ប្រុស | អនុប្រធាននាយកដ្ឋាន | អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (CCF) | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 23. | អ៊ឹង សូនីតា | ស្រី | ប្រធានការិយាល័យ | ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 24. | ឧក ស៊ីនណារ៉ា | ប្រុស | មន្ត្រី | មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប | បញ្ចប់ | បញ្ចប់ | បញ្ចប់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 25. | អូន វាសនា | ប្រុស | Staff | នាយកដ្ឋានកិច្ចការពិព័រណ៍ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 26. | ពាង តាំងលីម | ស្រី | អនុប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 27. | ផាន វ៉ាន់ថា | ស្រី | ប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 28. | ភឹម គន្ធា | ស្រី | អនុប្រធានការិយាល័យ | ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 29. | ពិន យាង | ប្រុស | អនុប្រធានការិយាល័យគ្រប់គ្រងពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 30. | ព្រហ្ម សុខេងវណ្ណារិទ្ធ | ប្រុស | អនុប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 31. | រាជ វុត្ថា | ប្រុស | មន្ត្រី | នាយកដ្ឋាននាំចេញនាំចូល | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 32. | រាជ្រា សុផារិដា | ស្រី | មន្ត្រី | នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 33. | សាន រ៉ូសាក់ | ប្រុស | អនុប្រធាននាយកដ្ឋាន | ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 34. | សៅ ចិន្តា | ប្រុស | មន្ត្រី | មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 35. | សែ សុគន្ធវឌ្ឍនា | ប្រុស | បុគ្គលិក | វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 36. | ស៊ិន សុខេង | ប្រុស | មន្ត្រី | ផែនការស្ថិតិ និងព័ត៌មានពាណជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 37. | ស៊ីវ លីមុី | ស្រី | មន្ត្រី | នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 38. | ស៊ីវ ទីប៉ | ប្រុស | មន្ត្រី | នាយកដ្ឋាននាំចេញនាំចូល | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 39. | សុខ ចាន់ដារ៉ា | ប្រុស | មន្ត្រី | មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 40. | ស៊ូ វង្សវិសេស | ប្រុស | មន្ត្រី | ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 41. | សុវណ្ណ វត្តីផាន | | | | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 42. | ទៀម សុម៉ាលីស | ស្រី | អនុប្រធានការិយាល័យ | វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវនៃក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 43. | តឹង ចាន់ទី | ប្រុស | អនុប្រធានការិយាល័យ | វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវនៃក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 44. | យ៉ាន ថារី | ស្រី | ប្រធានការិយាល័យ | អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "CCF" | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 45. | យាង សុខបញ្ញា | ស្រី | មន្ត្រី | ក្រសួងពាណិជ្ជកម្ម | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 46. | យស់ សុខា | ប្រុស | អនុប្រធាន | អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (CCF) | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 47. | យក់ វណ្ណា | ប្រុស | ប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តត្បូងឃ្មុំ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| 48. | ផេង ឌីណា | ប្រុស | អនុប្រធានការិយាល័យ | នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម | បញ្ចប់ | មិនបានចុះឈ្មោះ | បញ្ចប់ |
| 49. | ណុប ចាន់វុទ្ធី | | | | បញ្ចប់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 50. | ផេង វណ្ណដា | ប្រុស | មន្ត្រី | នាយកដ្ឋាននាំចេញនាំចូល | បញ្ចប់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 51. | អាន វណ្ណៈ | ប្រុស | អនុប្រធានការិយាល័យ | នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម | មិនបានបញ្ចប់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 52. | ជិនកេត តុលា | ប្រុស | ប្រធានការិយាល័យបណ្ដុះបណ្ដាល | វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវ | មិនបានបញ្ចប់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 53. | Jayco Valmon | | | | មិនបានបញ្ចប់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 54. | សុំ សុធា | | | | មិនបានបញ្ចប់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 55. | យ៉ាងនី ចរិយា | ស្រី | អនុប្រធានការិយាល័យ | វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវ | មិនបានបញ្ចប់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 56. | យី ចាន់សុខលីម | ស្រី | អនុប្រធានការិយាល័យ | វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវ | មិនបានបញ្ចប់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 57. | ជា រតនា | ប្រុស | មន្ត្រី | មន្ទីរពាណិជ្ជកម្មខេត្តពោធិ៍សាត់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 58. | ឆេង ឡេង | ប្រុស | អនុប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តក្រចេះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 59. | ឈឹម ទិតបុផានី | ស្រី | អនុប្រធានការិយាល័យ | វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 60. | ឈិន ឆដាភា | ស្រី | អនុប្រធានការិយាល័យ | ក្រសួងពាណិជ្ជកម្ម | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 61. | ជ្រិច គា | ស្រី | មន្ត្រី | នាយកដ្ឋានពាណិជ្ជកម្ម | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 62. | ឡេង ប៊ុនធឿន | ប្រុស | អនុប្រធានមន្ទីរ | អនុប្រធាន | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 63. | ខាំ ចាន់សុភ័ក្តិ | ប្រុស | អនុប្រធានការិយាល័យ | វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 64. | គឹម រស្មី | ប្រុស | អនុប្រធាននាយកដ្ឋាន | ពាណិជ្ជកម្មបៃតង | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 65. | ម៉ាណែត ផុស | ស្រី | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានកិច្ចការពិព័រណ៍ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 66. | មាស សុវណ្ណារី | ស្រី | អនុប្រធានការិយាល័យ | នាយកដ្ឋានកិច្ចការច្បាប់ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 67. | នូ ម៉ានីន | ស្រី | មន្ត្រី | មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 68. | នូរ៉ារិទ្ធ សេង | ប្រុស | ភ្នំពេញ | នាយកដ្ឋានពាណិជ្ជកម្មនៃរាជធានីភ្នំពេញ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 69. | នុត ពុទ្ធី | ប្រុស | មន្ត្រី | នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 70. | ផាត វ័ត្ថធីម៉ា | ស្រី | មន្ត្រី | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 71. | ព្រហ្ម លក្ខណា | ស្រី | អនុប្រធានការិយាល័យ | ក្រសួងពាណិជ្ជកម្ម | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 72. | វ័ត្ថ ចរិយា | ស្រី | មន្ត្រី | មន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 73. | សាផា ទូស | ប្រុស | អនុប្រធាននាយកដ្ឋានរដ្ឋបាល | អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (MoC) | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 74. | សឿង ពិសែន | ប្រុស | មន្ត្រី | មន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 75. | សុខ ឈន់ | ប្រុស | មន្ត្រី | ក្រសួងពាណិជ្ជកម្ម | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 76. | សយ សុធារី | ស្រី | បុគ្គលិក | វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវនៃក្រសួងពាណិជ្ជកម្ម | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |
| 77. | សួន ចាន់សេង | ប្រុស | អនុប្រធានការិយាល័យ | មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ | មិនបានចុះឈ្មោះ |

សម្គាល់៖

១. បញ្ចប់ = វគ្គសិក្សា និងសំណួរធ្វើតេស្តចុងក្រោយត្រូវបានបញ្ចប់ដោយជោគជ័យ។

២. មិនបានបញ្ចប់ = បានចុះឈ្មោះសម្រាប់វគ្គសិក្សា ប៉ុន្តែមិនបានបញ្ចប់ និង/ឬមិនបានឆ្លងកាត់សំណួរវាយតម្លៃ។

៣. មិនបានចុះឈ្មោះ = មានឈ្មោះនៅក្នុងបញ្ជីដែលផ្តល់ជូនដោយ MoC សម្រាប់ការធ្វើតេស្ត ប៉ុន្តែមិនបានចុះឈ្មោះសម្រាប់វគ្គសិក្សា។

# ឧបសម្ព័ន្ធទី៥

## សំណួរមតិត្រឡប់

**១. សំណួរទាក់ទងនឹងខ្លឹមសារនៃវគ្គសិក្សា៖** នៅលើមាត្រដ្ឋានពី ១ ដល់ ៥ (៥ ខ្ពស់បំផុត) តើអ្នកបានយល់ឃើញថាវគ្គសិក្សានេះមានសារប្រយោជន៍ខ្លាំងប៉ុណ្ណា ក្នុងការសិក្សាអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក?

**២. សំណួរទាក់ទងនឹងបទពិសោធន៍សិក្សា៖** នៅលើមាត្រដ្ឋានពី ១ ដល់ ៥ (៥ ខ្ពស់បំផុត) តើអ្នកយល់ថា បន្ទុកការងារនៃវគ្គសិក្សានេះមានភាពគ្រប់គ្រាន់ដល់កម្រិតណា ចំពោះការសិក្សាអំពីប្រធានបទនៃវគ្គសិក្សានោះ?

